ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កងយោធពលខេមរភូមិន្ទ

ច្បាប់ អនុក្រឹត្យ ប្រកាសអន្តរក្រសួង ប្រកាស

ព្រមទាំង ឯកសារឧបសម្ព័ន្ធ និងសេចក្តីណែនាំ ផ្សេងៗ ស្តីអំពីការអនុវត្តន៍

របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ

ចំពោះយោធិនអាជីព នៃកងយោធពលខេមរភូមិន្ទ

# មាតិកា


១-ព្រះរាជក្រមលេខ ០៧/នស/៥៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ប្រកាសអោយប្រើច្បាប់ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

២-ព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ប្រកាសអោយប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

៣-អនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ។

៤-ប្រកាសលេខ ០១២/២០០៧ ប្រក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់ក្រសួងការពារជាតិ ស្តីពីការណែនាំអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ។

- **ឧបសម្ព័ន្ធ :** ជីវប្រវត្តិពិស្តារ និង ប័ណ្ណពត៌មានផ្ទាល់ខ្លួន ។

៥-ប្រកាសអន្តរក្រសួងលេខ ១២៨/២០០៧ ប្រក.អន ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ របស់ក្រសួងការពារជាតិ. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រសួងសុខាភិបាល ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃកំរិតថ្នាក់បាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ។

- **ឧបសម្ព័ន្ធ :** ការកំណត់ប្រភេទកំរិតថ្នាក់បាត់បង់សមត្ថភាពការ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

៦-ប្រកាសអន្តរក្រសួងលេខ ១៣០/២០០៧ ប្រក.អន ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ របស់ក្រសួងការពារជាតិ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកំណត់ប្រាក់ធ្វើដំណើរ ប្រាក់ហូបចុកទាំងទៅទាំងមក និងប្រាក់ឧបត្ថម្ភ ដើម្បីប្រុងប្រៀបជីវភាពរស់នៅក្នុងគ្រួសាររបស់យោធិនអាជីពទាំងពីរភេទ ដែលបានច្បាប់ឈប់សម្រាកក្នុងប្រទេសមុនពេលចូលនិវត្តន៍ ។

៧-លិខិតលេខ ០០៦/២០០៨ ស.ណ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៨ របស់ក្រសួងការពារជាតិ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃកំរិតថ្នាក់បាត់បង់សមត្ថភាពការងារ ថ្នាក់អន្តរក្រសួង ថ្នាក់ក្រសួង និងថ្នាក់តំបន់ប្រតិបត្តិការសឹករងខេត្ត-ក្រុង ។

៨-លិខិតលេខ ០០៧/២០០៨ ស.ណ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៨ របស់ក្រសួងការពារជាតិ ស្តីពីការបំពេញជីវប្រវត្តិពិស្តារ ចំពោះយោធិនស្ថិតក្នុងស្ថានភាពចូលនិវត្តន៍តាមការកំណត់ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ០៧ ន.ស.៩៤

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស

អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើនៅថ្ងៃទី២៤-៩-១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១-១១-១៩៩៣
- គណៈរដ្ឋមន្ត្រីបានយល់ព្រមផង

## <u>ប្រកាសអោយប្រើ</u>

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នាថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទដូចមានសេចក្តីតទៅនេះ ÷

# ជំពូកទី ១
## របបសោធននិវត្តន៍

មាត្រា ១

យោធិនទាំង ២ ភេទ ដែលបានបំពេញការងារក្នុងកងយោធពលខេមរភូមិន្ទ អាចចូលនិវត្តន៍បាន លុះត្រាតែបំពេញលក្ខខណ្ឌខាងក្រោម ៖

ក _ បុរសត្រូវមានអាយុ ៥៥ ឆ្នាំ និងមានរយៈពេលបំពេញការងាររួម ២០ ឆ្នាំ យ៉ាងតិច ។

ខ _ នារីត្រូវមានអាយុ ៥០ ឆ្នាំ និងមានរយៈពេលបំពេញការងាររួម ១៥ ឆ្នាំ យ៉ាងតិច ។

រយៈពេលបំពេញការងារ ២០ ឆ្នាំ និង ១៥ ឆ្នាំខាងលើនេះ ត្រូវមានរយៈពេលបំពេញការងារក្នុងកងយោធពលខេមរភូមិន្ទយ៉ាងតិច ៥ ឆ្នាំ ជាបន្តបន្ទាប់មុនពេលចូលនិវត្តន៍ ។

មាត្រា ២_

យោធិនទាំង ២ ភេទ នៃកងយោធពលខេមរភូមិន្ទ អាចទទួលរបបសោធននិវត្តន៍បានត្រូវមានលក្ខខណ្ឌដូចខាងក្រោម ៖

ក _ របបសោធននិវត្តន៍អតិបរមា

១ _ យោធិនដែលបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់នេះ ឬ

២ _ ចំពោះយោធិនដែលបានបំពេញការងារនៅទីចង្អៀតតឹង ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពចំនួន ១០ ឆ្នាំ ចំពោះបុរស និង ៨ ឆ្នាំ ចំពោះនារី លក្ខខណ្ឌអាយុនិងរយៈពេលបំពេញការងាររួមត្រូវបន្ថយ ៥ ឆ្នាំ ឬ

៣ _ ចំពោះយោធិនដែលបានបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពចំនួន ១២ ឆ្នាំ ចំពោះបុរស និង ៥ ឆ្នាំ ចំពោះនារី ហើយមានអាយុ ១ ឆ្នាំ ហើយគ្រប់លក្ខខណ្ឌរយៈពេលបំរើការងាររួចហើយ ឬ

៤ _ ចំពោះយោធិនដែលបានបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពចំនួន ១៥ ឆ្នាំ ចំពោះបុរស និង ១០ ឆ្នាំ ចំពោះនារី ដែលបានគ្រប់លក្ខខណ្ឌរយៈពេលបំរើការងារដូចមានចែងក្នុងមាត្រា ១ ខ ឬ

៥ _ ចំពោះយោធិនដែលបានបំរើការងារផ្សេងៗ ក្នុងកងយោធពលខេមរភូមិន្ទ ចំនួន ២០ ឆ្នាំ ចំពោះបុរស និង ១៥ ឆ្នាំ ចំពោះនារី ដែលបានគ្រប់លក្ខខណ្ឌរយៈពេលបំរើការងារដូចមានចែងក្នុងមាត្រា ១ ខ ។

ខ _ របបសោធននិវត្តន៍អតិបរមា ៖

១ _ បុរសត្រូវមានអាយុ ៥៥ ឆ្នាំ និងរយៈពេលបំរើការងារក្នុងកងយោធពលខេមរភូមិន្ទចំនួន ២០ ឆ្នាំ នារីត្រូវមានអាយុ ៥០ ឆ្នាំ និងរយៈពេលបំរើការងារក្នុងកងយោធពលខេមរភូមិន្ទចំនួន ១៥ ឆ្នាំ ឬ

២ _ បុរសត្រូវមានអាយុ ៥០ ឆ្នាំ និងរយៈពេលបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពចំនួន ១៥ ឆ្នាំ ក្នុងកងយោធពលខេមរភូមិន្ទ ។ នារីត្រូវមានអាយុ ៤៥ ឆ្នាំ និងរយៈពេលបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ចំនួន ១០ ឆ្នាំ ក្នុងកងយោធពលខេមរភូមិន្ទ ឬ

៣ _ ឧត្តមសេនីយ៍ ឬវីរជន ក្នុងកងយោធពលខេមរភូមិន្ទដែលបានបំពេញលក្ខខណ្ឌដូចមានចែងនៅចំណុច "ក" ក្នុងមាត្រា ២ ត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមា ឬ

៤ _ ចំពោះយោធិនពិការដែលនៅបំរើការងារជាប់រហូតដល់ចូលនិវត្តន៍ ត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមាដូចមានចែងក្នុងចំណុច "ខ" នៃមាត្រា ២ ។

មាត្រា ៣ _

របៀបគិតរយៈពេលបំរើការងារព្រមទាំងការកំណត់តំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពដែលមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៤.

យោធិនរាជការ ដែលមិនបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុច "ក" មាត្រា ២ នៃ ច្បាប់នេះ មិនទទួលប្រាក់សោធននិវត្តន៍ឡើយ តែទទួលប្រាក់ឧបត្ថម្ភផ្ដាច់មួយដង ស្មើនឹងបៀវត្សរ៍ប្រចាំខែចុងក្រោយ គុណនឹងចំនួនឆ្នាំនៃរយៈពេលបំរើការងារ ។ ប្រាក់ឧបត្ថម្ភនេះមិនត្រូវតិចជាងបៀវត្សរ៍ ៦ ខែចុងក្រោយរបស់សាមីខ្លួនឡើយ ។

មាត្រា ៥.

ប្រាក់សោធននិវត្តន៍ត្រូវកំណត់ដូចខាងក្រោម ៖

១. ប្រាក់សោធននិវត្តន៍អប្បបរមាប្រចាំខែស្មើ ៥០ ភាគរយនៃបៀវត្សរ៍តាមឋានន្តរសក្តិប្រចាំខែចុងក្រោយ ។ ប្រាក់នេះត្រូវបានបន្ថែម ១ឆ្នាំ ២ ភាគរយទៀត រាប់ចាប់ពីឆ្នាំទី ៤ នៃរយៈពេលបំរើការងារយោធា ឬ ចាប់ពីឆ្នាំទី ៦ នៃរយៈពេលបំរើការងាររដ្ឋ ។ តែសរុបមិនត្រូវលើស ៨០ ភាគរយនៃប្រាក់សោធននិវត្តន៍អតិបរមាឡើយ ។

២. ប្រាក់សោធននិវត្តន៍អតិបរមាប្រចាំខែស្មើ ៨០ ភាគរយនៃបៀវត្សរ៍តាមឋានន្តរសក្តិប្រចាំខែចុងក្រោយ ។

៣. ប្រាក់សោធននិវត្តន៍ទាបបំផុតមិនត្រូវតិចជាងបៀវត្សរ៍តាមឋានន្តរសក្តិអប្បបរមារបស់ពលទាហានឡើយ ។

៤. យោធិនដែលបានចូលបំរើការងារក្នុងជួរយោធាមុនឆ្នាំ ១៩៧០ ឬវីរជនត្រូវបានបន្ថែម ២០ ភាគរយនៃបៀវត្សរ៍តាមឋានន្តរសក្តិថែមទៀត ។

៥. យោធិនដែលចូលបំរើការងារក្នុងជួរយោធាមុនឆ្នាំ ១៩៧៩ ត្រូវបានបន្ថែម ១៥ ភាគរយនៃបៀវត្សរ៍តាមឋានន្តរសក្តិថែមទៀត ។

៦. យោធិនដែលធ្វើការនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ត្រូវបានបន្ថែម ១៥ ភាគរយនៃបៀវត្សរ៍តាមឋានន្តរសក្តិថែមទៀត ។

មាត្រា ៦.

របបបន្ថែមផ្សេងៗសម្រាប់ចូលនិវត្តន៍ ៖

១. ត្រូវទទួលប្រាក់បន្ថែមមួយលើកស្មើ ៨ ខែ នៃបៀវត្សរ៍ប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

២. អាចសុំច្បាប់ឈប់សម្រាកពី ៦ ទៅ ១២ ខែ ពិតតាមឋានន្តរសក្តិ និងករណីចាំបាច់របស់យោធិនម្នាក់ៗមុនពេលចូលនិវត្តន៍ ។

ក្រោយពីទទួលពិនិត្យហើយ បើមានជំងឺ ឬប្រការផ្ទាល់ ឬការរបួសដែលត្រូវការព្យាបាលរយៈ សម្ភពបន្ត នោះការផ្តល់សិទ្ធិនិវត្តន៍ទៀត ។

មាត្រា ៧ .

យោធិនទាំង ២ ភេទចូលនិវត្តន៍ ឬបាត់បង់សមត្ថភាពការងារមានសិទ្ធិស្នើសុំតាំងលំនៅឋានរស់នៅ តាមគោលបំណងរបស់ខ្លួនក្នុងភូមិកំណើតឬតាមឆន្ទៈ ។ ក្រសួងការពារជាតិត្រូវជួយឧបត្ថម្ភ ។

មាត្រា ៨ .

យោធិនទាំងឡាយណាដែលបានបំពេញលក្ខខណ្ឌចូលនិវត្តន៍ អាចបន្តការងារ ១ឆ្នាំម្តងៗដោយមានការស្នើសុំពីសាមីខ្លួន និងមានការយល់ព្រមពីស្ថាប័នមានសមត្ថកិច្ចផង ។

រយៈពេលសុំបន្តការងារមិនអាចហួសពី ៥ ឆ្នាំឡើយ ។

## ជំពូកទី ២
## របបសោធនបាត់បង់សមត្ថភាពការងារ

មាត្រា ៩ .

យោធិនទាំងពីរភេទដែលបាត់បង់សមត្ថភាពការងារ ៖

ក. ដោយសារជំងឺរ៉ាំរ៉ៃ ចាស់ជរា គ្រោះថ្នាក់ផ្សេងៗដែលមិនបាត់បង់អវយវៈណាមួយ ហើយមិនគ្រប់លក្ខណៈជាយោធិននិវត្តន៍ អាចទទួលរបបសោធនបាត់បង់សមត្ថភាពការងារបាន លុះត្រាតែបានបំពេញការងារយ៉ាងតិច ១៥ ឆ្នាំ ចំពោះបុរស និង ១០ ឆ្នាំ ចំពោះនារី ។

រយៈពេល ១៥ ឆ្នាំ និង ១០ ឆ្នាំ ខាងលើនេះ ត្រូវមានរយៈពេលបំពេញការងារក្នុងជួរយោធិនខេមរភូមិន្ទយ៉ាងតិច ៥ ឆ្នាំ ជាបន្តបន្ទាប់មុនពេលទទួលបាត់បង់សមត្ថភាពការងារ ។

ខ. ដោយសារបំពេញភារកិច្ចធ្វើការនៅជួរមុខ ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ដោយពុំគិតពីអាយុ និងរយៈពេលបំពេញការងារឡើយ ហើយត្រូវបានគិតការបាត់បង់សមត្ថភាពការងារជា ៣ ថ្នាក់ដូចខាងក្រោម ៖

- ថ្នាក់ទី ១ បាត់បង់សមត្ថភាពការងារលើសពី ៨០ ភាគរយ
- ថ្នាក់ទី ២ បាត់បង់សមត្ថភាពការងារលើសពី ៦០ ភាគរយ
- ថ្នាក់ទី ៣ បាត់បង់សមត្ថភាពការងារលើសពី ៤០ ភាគរយ ។

មាត្រា ១០.-

លក្ខខណ្ឌនានាសម្រាប់ការបាត់បង់សមត្ថភាពការងារសម្រាប់ថ្នាក់និមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ

មាត្រា ១១.-

យោធិនទាំងឡាយ ដែលបាត់បង់សមត្ថភាពការងារ ដែលមិនបានបំពេញលក្ខខណ្ឌដូចមានចែងនៅក្នុងមាត្រា ៩ នៃច្បាប់នេះ ពុំមានសិទ្ធិទទួលប្រាក់សោធនបាត់បង់សមត្ថភាពការងារឡើយ ។ ករណីនេះ ត្រូវទទួលប្រាក់ឧបត្ថម្ភមួយលើកគត់ ស្មើបៀវត្សរ៍របស់ខ្លួន គុណនឹងចំនួនឆ្នាំដែលបានបំពេញការងារ ប៉ុន្តែចំនួនប្រាក់នេះ មិនត្រូវតិចជាងបៀវត្សរ៍ ៦ ខែរបស់សាមីខ្លួនឡើយ ។

មាត្រា ១២.-

ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ចែកចេញជាពីរថ្នាក់ដូចខាងក្រោម ៖

ក.- ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែស្មើនឹង ៥០ ភាគរយ នៃបៀវត្សរ៍មូលដ្ឋានចុងក្រោយត្រូវបានផ្តល់ចំពោះ ៖

១.- យោធិនដែលបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងចំណុច " ក " ក្នុងមាត្រា ៩ នៃច្បាប់នេះ ។

២.- យោធិនដែលបានបំពេញការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬប៉ះពាល់សុខភាពចំនួន ១០ ឆ្នាំ ចំពោះបុរស និង ៨ ឆ្នាំ ចំពោះនារី ។

ប្រាក់សោធនបាត់បង់សមត្ថភាពការងារអប្បបរមាប្រចាំខែស្មើ ៥០ ភាគរយ នៃបៀវត្សរ៍មូលដ្ឋានប្រចាំខែចុងក្រោយ ត្រូវបានបន្ថែម ១ ឆ្នាំ ១.៥ ភាគរយទៀតចាប់ពីឆ្នាំទី ៤ នៃរយៈពេលបំពេញការងារយោធា ឬចាប់ពីឆ្នាំទី ៦ នៃរយៈពេលបំពេញការងារ ។ ដែលប្រាក់សរុបមិនត្រូវលើស ៦០ ភាគរយ នៃប្រាក់សោធនបាត់បង់សមត្ថភាពការងារឡើយ ។

ខ.- ប្រាក់សោធនបាត់បង់សមត្ថភាពការងារ ៖

- យោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី ១ ទទួលបាន ១០០ ភាគរយ នៃបៀវត្សរ៍មូលដ្ឋានប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

- យោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី ២ ទទួលបាន ៨០ ភាគរយ នៃបៀវត្សរ៍មូលដ្ឋានប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

- យោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី ៣ ទទួលបាន ៦០ ភាគរយ នៃបៀវត្សរ៍មូលដ្ឋានប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

ត្រូវទទួលបាន [illegible] ស្មើនឹង ៤០ ភាគរយនៃ [illegible]
[illegible] របស់ខ្លួនទៀត ។

យោធិនដែលរងរបួសដោយសារបំពេញបេសកកម្ម [illegible] ត្រូវទទួលបានអត្រាបន្ថែម [illegible] ភាគរយនៃបៀវត្សរ៍បន្ទាប់បន្សំថែមទៀត ។

យោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី ១ ត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែបន្ថែមសម្រាប់អ្នកជំនួយកិច្ចការក្នុងផ្ទះស្មើនឹងប្រាក់បៀវត្សរ៍គោល និងប្រាក់បំណាច់របស់ពលទាហានម្នាក់ ។

ចំពោះវីរជននៃកងយោធពលខេមរភូមិន្ទត្រូវបានទទួលអត្រាបន្ថែម ១០ ភាគរយ នៃបៀវត្សរ៍បន្ទាប់បន្សំថែមទៀត ។

មាត្រា ១៣._

របបបន្ថែមផ្សេងៗចំពោះយោធិនបាត់បង់សមត្ថភាពការងារ ៖

១._ ត្រូវបានទទួលប្រាក់បន្ថែម ១ លើកស្មើនឹង ៦ ខែ នៃបៀវត្សរ៍ប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

២._ បើគ្មានទីលំនៅ អ្នកទទួលបាន [illegible] ។ ក្នុងករណីនេះ សាមីខ្លួនទទួលប្រាក់បន្ថែមរហូតដល់ ៥០ ភាគរយប៉ុណ្ណោះ ។

៣._ ពេលមានជំងឺ គ្រោះថ្នាក់ ឬស្លាប់ត្រូវបានទទួលរបបដូចនៅរាជការ [illegible] យោធិនបម្រើការ ។

មាត្រា ១៤._

ប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារ ក្រោយមរណភាពរបស់វីរជន និងអ្នកបាត់បង់សមត្ថភាពការងារ ត្រូវបានផ្តល់ជូនក្រុមគ្រួសារដែលមានតម្លៃស្មើនឹងប្រាក់បៀវត្សរ៍ និងប្រាក់បំណាច់របស់សាមីជន គុណនឹង ១២ ខែ ។

## ជំពូកទី ៣
## អំពីអន្តរប្បញ្ញត្តិ

មាត្រា ១៥._

ប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងាររបស់យោធិន នៃកងយោធពលខេមរភូមិន្ទ មិនអាចតិចជាងប្រាក់ឧបត្ថម្ភ [illegible] ស្មើនឹង ៦ ភាគរយ នៃបៀវត្សរ៍បន្ទាប់បន្សំរបស់យោធិនម្នាក់ៗ ។

## ជំពូកទី ៤ ៤

## អវសានប្បញ្ញត្តិ

មាត្រា ១៦ -

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីច្បាប់នេះ ត្រូវទុកជានិរាករណ៍

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៤

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាប់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

បានបង្គំគាល់ថ្វាយ និងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ទៀ បាញ់ ធា ចំរ៉ាត់

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

ព្រះរាជក្រម

នស / រកម / ០៥០៦ / ០០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

មហាឧភតោសុជាតខត្តិយវង្ស ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ

ខត្តិយារាជ សមូហោភាស ឯកឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ [illegible] ស្តីពី [illegible] និង [illegible] ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០១ ខែ [illegible] ឆ្នាំ ២០០៦ ក្នុងសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមពេលកំណត់របស់មាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# វិសោធនកម្ម

# ច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

មាត្រា មួយ.–

មាត្រា ១ និងមាត្រា ២ នៃច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម :

មាត្រា ១ .– ថ្មី

យោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ត្រូវដាក់ឱ្យចូលនិវត្តន៍ អាស្រ័យតាមលក្ខខណ្ឌដូចខាងក្រោម :

១-នាយទាហានចាប់ពីថ្នាក់វរសេនីយ៍ឯក និងវរនាវីឯកឡើងទៅ នៅពេលដល់អាយុ ៦០ (ហុកសិប) ឆ្នាំ

២-នាយទាហានថ្នាក់វរសេនីយ៍ទោ និងវរនាវីទោ នៅពេលដល់អាយុ ៥៨ (ហាសិបប្រាំបី) ឆ្នាំ

៣-នាយទាហានចាប់ពីថ្នាក់នាយចំណាត់ និងនាយនាវីចំណាត់ ដល់ថ្នាក់វរសេនីយ៍ត្រី និងវរនាវីត្រី នៅពេលដល់អាយុពី ៤៣ (សែសិបបី) ឆ្នាំ ទៅ ៥៥ (ហាសិបប្រាំ) ឆ្នាំ ។

៤-នាយទាហានរងចាប់ពីថ្នាក់ពលបាលត្រី និងចក្របាលត្រី ដល់ថ្នាក់ព្រិន្ទុបាលឯក និងនាយចក្របាលឯក នៅពេលដល់អាយុពី ៣៨ (សាមសិបប្រាំបី) ឆ្នាំ ទៅ ៤២ (សែសិបពីរ) ឆ្នាំ ។

នាយទាហានថ្នាក់ឧត្តមសេនីយ៍ ឧត្តមនាវីវរជន និងវរសេនីយ៍ឯក កងទ័ពជើងអាកាស វរនាវីឯកកងទ័ពជើងទឹក ដែលមានគុណសម្បត្តិនិងសមត្ថភាព ឬជាអ្នកជំនាញឯកទេស ទោះបីដល់អាយុចូលនិវត្តន៍ក៏ដោយ តាមការស្នើសុំរបស់សាមីខ្លួន ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬតាមតម្រូវការចាំបាច់របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចត្រូវរក្សាទុកដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ប្រទេសជាតិ ។

យោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ អាចស្នើសុំចូលនិវត្តន៍មុនពេលកំណត់បាន ។

លក្ខខណ្ឌ និងបែបបទនៃការចូលនិវត្តន៍តាមការកំណត់និងការចូលនិវត្តន៍មុនពេលកំណត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ២ ._ ថ្មី

យោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទអាចទទួលរបបសោធននិវត្តន៍បាន ត្រូវមានលក្ខខណ្ឌដូចខាងក្រោម :

ក-របបសោធននិវត្តន៍អប្បបរមា

១-ចំពោះយោធិនអាជីព ដែលបានបំពេញការងារនៅតំបន់គ្រោះថ្នាក់ ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពយ៉ាងតិច ១០ (ដប់) ឆ្នាំ ចំពោះបុរស និងយ៉ាងតិច ៨ (ប្រាំបី) ឆ្នាំ ចំពោះនារី ។

២-ចំពោះយោធិនអាជីពដែលបានបំពេញការងារមិនប៉ះពាល់ដល់សុខភាព ឬគ្រោះថ្នាក់ជាប់ៗចំនួន ២០ (ម្ភៃ) ឆ្នាំ ចំពោះបុរស និងចំនួន ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះនារី ។

ខ-របបសោធននិវត្តន៍អតិបរមា

១-ចំពោះយោធិនអាជីព ដែលបានបំពេញការងារនៅតំបន់លំបាក ការ

ការគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពលើសពី ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបុរស និងលើសពី ១២ (ដប់ពីរ) ឆ្នាំ ចំពោះនារី ។

២-ចំពោះយោធិនអាជីពដែលបានបំពេញការងារមិនប៉ះពាល់ដល់សុខភាព ឬគ្រោះថ្នាក់ផ្សេងៗលើសពី ២០ (ម្ភៃ) ឆ្នាំ ចំពោះបុរស និងលើសពី ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះនារី ។

៣-ចំពោះឧត្តមសេនីយ៍ ឧត្តមនាវី ឬវីរជនក្នុងកងយោធពលខេមរភូមិន្ទដែលបានបំពេញបេសកកម្មដូចមានចែងនៅចំណុច (ក) ខាងលើ ត្រូវបានទទួលបៀវត្សនិវត្តន៍អតិបរមា ។

៤-ចំពោះយោធិនពិការដែលនៅបំពីការងារជាប់រហូតដល់អាយុចូលនិវត្តន៍ ។

ដោយឡែក លក្ខខណ្ឌ និងបែបបទស្តីពីរបបសន្តិសុខសង្គមចំពោះយោធិនពិការដែលបំពីការងារមិនបាន យោធិនពលី មរណៈ បង្គស្លាប់ និងពាក់ព័ន្ធ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៧៩.–

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៧ ខែមករា ឆ្នាំ ២០០៦

ពរល.០១០៦.១៧២ ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានចម្លងជូនសម្តេចនាយករដ្ឋមន្ត្រី

<u>ចម្លងជូន</u>

ថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៦ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ លេខ: ១៧៦ ក.ព

ហត្ថលេខា

ទៀ បាញ់

- អគ្គបញ្ជាការដ្ឋាន
- អគ្គលេខាធិការដ្ឋាន
- ពា អគ្គនាយក
- នាយកដ្ឋាន ស្ថាប័នចំណុះ

(ដើម្បីជ្រាប) ...

ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញថ្ងៃទី ខែ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពនៅក្រៅពីជួរនៃកងយោធពលខេមរភូមិន្ទ

(១៩៩២១៩៩៣)

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក. ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សេចក្តីសម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់លក្ខខណ្ឌនៃការចូលនិវត្តន៍តាមការកំណត់ ការចូលនិវត្តន៍មុនពេលកំណត់ និងលក្ខខណ្ឌនៃការទទួលរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទ នៃកងយោធពលខេមរភូមិន្ទ សំដៅអនុវត្តច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ និងច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២.-** ដើម្បីអនុវត្តអនុក្រឹត្យនេះ ពាក្យដូចខាងក្រោម ត្រូវកំណត់និយមន័យដូចតទៅ :

- របបសោធននិវត្តន៍ គឺជាគោលរបបពិតជាទឹកប្រាក់ ដែលរដ្ឋត្រូវផ្តល់អោយយោធិនម្នាក់ៗ ដែលបានបំពេញតាមលក្ខខណ្ឌចូលនិវត្តន៍ និងរយៈពេលបំរើការងារ ។

- របបបាត់បង់សមត្ថភាពការងារ គឺជាគោលរបបពិតជាទឹកប្រាក់ ដែលរដ្ឋត្រូវផ្តល់អោយយោធិនម្នាក់ៗ ដែលតាមសកម្មភាពបំពេញការងាររបស់ខ្លួនកន្លងមក មានផលប៉ះពាល់សុខភាព ដោយមិនអាចបន្តការងារទៀតបាន ហើយត្រូវបានចាត់ចូលក្នុង ប្រភេទបាត់បង់សមត្ថភាពការងារ ។

- របបចេញពីជួរ គឺជាទឹកប្រាក់ដែលត្រូវផ្តល់អោយយោធិនណាដែលបានបញ្ចប់ការកិច្ចជាយោធិនអាជីព ហើយមិនបានបំពេញគ្រប់លក្ខខណ្ឌចូលនិវត្តន៍ និងមិនត្រូវបានចាត់ចូលក្នុងប្រភេទបាត់បង់សមត្ថភាពការងារ ។

## ជំពូកទី២

## របបសោធននិវត្តន៍

**មាត្រា៣.-**

យោធិនអាជីព អាចចូលនិវត្តន៍បានតាមការកំណត់ លុះត្រាតែបានបំពេញលក្ខខណ្ឌដូចខាងក្រោម÷

**ក-នាយទាហាន :**

| | | |
|---|---|---|
| ១-ថ្នាក់វរសេនីយ៍ឯក | និងវរនាវីឯកឡើងទៅ | **នៅពេលដល់អាយុ ៦០ ឆ្នាំ** |
| ២-ថ្នាក់វរសេនីយ៍ទោ | និងវរនាវីទោ | នៅពេលដល់អាយុ ៥៨ ឆ្នាំ |
| ៣-ថ្នាក់វរសេនីយ៍ត្រី | និងវរនាវីត្រី | នៅពេលដល់អាយុ ៥៥ ឆ្នាំ |
| ៤-ថ្នាក់អនុសេនីយ៍ឯក | និងអនុនាវីឯក | នៅពេលដល់អាយុ ៥៣ ឆ្នាំ |

របស់យោធិនម្នាក់ៗ ត្រូវបានកំណត់ដូចខាងក្រោម ÷

**១_របៀបគិតរយៈពេលបំរើការងារ :**

ការគិតរយៈពេលបំរើការងារ គឺបានគិតរួមទាំងរយៈពេលបំរើការងារគ្រប់របបសង្គម "បើមាន" និងរយៈពេលបំរើការងារស៊ីវិល និងកងយោធពលខេមរភូមិន្ទដោយ :

**ក-ត្រូវចាត់ទុកជារយៈពេលបំរើការងារ :**

ការចាត់ទុកជារយៈពេលបំរើការងារ គឺគិតចាប់តាំងពីមន្ត្រីរាជការ បុគ្គលិក កម្មកររដ្ឋ ដែលបានបញ្ចូលមកក្នុងក្របខណ្ឌ "រដ្ឋពេញសិទ្ធិ" រួចក្រោយមក ចូលបំរើក្នុងកងយោធពលខេមរភូមិន្ទ ឬចាប់ពីពេលចូលបំរើក្នុងកងយោធពលខេមរភូមិន្ទជាបំរុងរហូត ដល់ពេលចុះនិវត្តន៍ ។ ស្ថានភាពនៃរយៈពេលបំរើការងារ ត្រូវបានគិតដូចខាងក្រោម ÷

-រយៈពេលធ្វើរដ្ឋបាល ភូមិ ឃុំ សង្កាត់ ឬចងជីវពល ដែលមានប្រាក់ឧបត្ថម្ភ
-រយៈពេលមន្ត្រីរាជការ បុគ្គលិក កម្មកររដ្ឋ ធ្វើការតាមក្រសួង ស្ថាប័នរដ្ឋនានា ឬរយៈពេលទៅធ្វើកម្មសិក្សាក្នុង ឬក្រៅប្រទេស
-រយៈពេលមន្ត្រីរាជការ ធ្វើការងារក្រៅប្រទេស
-រយៈពេលបំរើការងារអតីតកាលតាមរបបសង្គម
-រយៈពេលបំរើការងារក្នុងកងយោធពលខេមរភូមិន្ទ
-រយៈពេលជាប់មន្ទីរឃុំឃាំង ដោយគ្មានទោសកំហុស
-រយៈពេលដែលយោធិនស្ថិតក្នុងកិច្ចសន្យា ។

**ខ-មិនត្រូវចាត់ទុកជារយៈពេលបំរើការងារ :**

-គឺជារយៈពេល ដែលគេប្រើរអោយមន្ត្រីរាជការ បុគ្គលិក កម្មកររដ្ឋ ធ្វើការសាកល្បង ។

**២_ការកំណត់តំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ដូចជា :**

តំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ត្រូវបានកំណត់ដូចខាងក្រោម ÷

**ក-តំបន់លំបាក :**

យោធិនបានបំពេញភារកិច្ចនៅតំបន់ដាច់ស្រយាល ឬកោះ តំបន់ព្រុនចាញ់ តំបន់ព្រៃភ្នំ លំបាកដោយអាកាសធាតុ ឬលំបាកដោយជីវភាពរស់នៅ និងសមរភូមិប្រយុទ្ធ ។

**ខ-ការងារគ្រោះថ្នាក់ :**

យោធិនជាអាកាសយានិក ទ័ពជំនាញឆ័ត្រយោង ទ័ពវិស្វកម្ម ជំនាញដោះមីន ទ័ពជំនាញផលិត ឬពិសោធន៍គ្រឿងផ្ទុះ ។

**គ-ការងារប៉ះពាល់សុខភាព :**

យោធិនជានាវិក ជាងជួសជុលគ្រឿងចក្រមុនឆ្វន់ បុគ្គលិកពេទ្យ ជាងអគ្គិសនី

អ្នកធ្វើការងារនៅអាគារថាមពលធ្យូង អាគារថង់ផ្ទុះ និងមន្ទីរពិសោធន៍ មន្ទីរពេទ្យ មេជំនាញគីមីសាស្ត្រ ជំនាញកាំភ្លើងធំ អ្នកបើកបរគ្រឿងចក្រធុនធ្ងន់ ។

ដើម្បីអនុវត្តឱ្យបានល្អ និងមានប្រសិទ្ធភាពនោះ ក្រសួងការពារជាតិត្រូវធ្វើប្រកាស កំណត់លំអិតអំពីលក្ខខណ្ឌជាក់ស្តែង ។

មាត្រា១៨.-

ប្រាក់សោធននិវត្តន៍រួមមាន បៀវត្សរ៍ឋានន្តរសក្តិ ត្រូវបានបូកបន្ថែមជាមួយប្រាក់ឧបត្ថម្ភលើបៀវត្សរ៍ឋានន្តរសក្តិ បូកប្រាក់ហូបប្រចាំខែ បូកប្រាក់បំណាច់មុខងារ "បើមាន" បូកប្រាក់បំណាច់តំបន់ "បើមាន" ។

មាត្រា១៩.-

យោធិនអាជីព ដែលមានគ្រប់លក្ខខណ្ឌ ត្រូវបានទទួលរបបសោធននិវត្តន៍ជាប្រចាំខែ ដូចមានចែងក្នុង ជំពូកទី ១ មាត្រា ៥ និងមាត្រា ៦ នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

ក្រៅពីទទួលរបបសោធននិវត្តន៍ប្រចាំខែ ដូចបានបញ្ជាក់ក្នុងកថាខណ្ឌខាងលើ ត្រូវបានទទួលរបបអ្នកនៅក្នុងបន្ទុកដែលរដ្ឋទទួលស្គាល់ ដូចនៅពេលបំពេញការងារ ។

មាត្រា២០.-

យោធិនអាជីព មុនពេលចូលនិវត្តន៍ អាចអនុញ្ញាតឈប់សម្រាកច្បាប់ ដោយផ្អែកលើករណីចាំបាច់ ដើម្បីត្រៀមរៀបជីវភាពរស់នៅក្នុងគ្រួសារ ដូចមានចែងក្នុងជំពូកទី ១ មាត្រា ៦ ចំណុច ២ នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

-ថ្នាក់ព្រិន្ទបាលឯកចុះ ត្រូវបានឈប់សម្រាក ៦ខែ

-ថ្នាក់នាយចំណង់ និងអនុសេនីយ៍ ត្រូវបានឈប់សម្រាក ៨ខែ

-ថ្នាក់វរសេនីយ៍ ត្រូវបានឈប់សម្រាក ១០ខែ

-ថ្នាក់ឧត្តមសេនីយ៍ ឬវីរជន ត្រូវបានឈប់សម្រាក ១២ខែ ។

នៅពេលឈប់សម្រាកច្បាប់ក្នុងប្រទេស ត្រូវបានទទួលប្រាក់ធ្វើដំណើរ ប្រាក់ហូបចុកតាមផ្លូវទាំងទៅ ទាំងមក តាមប្រកាសកំណត់របស់ក្រសួងការពារជាតិ ។

មាត្រា២១.-

យោធិនអាជីព ដែលមានវិន័យ គុណសម្បត្តិ សមត្ថភាព និងសុខភាពល្អ ឬជាអ្នកជំនាញឯកទេស ដែលដល់អាយុកំណត់ចូលនិវត្តន៍ អាចសុំបន្តបំពេញការងារ ១ឆ្នាំម្តង ដោយមានការយល់ព្រម ពីរដ្ឋមន្ត្រីក្រសួងការពារជាតិ មានសិទ្ធិដូចខាងក្រោម ÷

១-ទទួលបៀវត្សរ៍ដូចក្នុងស្ថានភាពសកម្ម

២-រយៈពេលបំពេញការងារបន្ត ត្រូវតែគិតក្នុងអតីតភាព ដើម្បីទទួលរបបសោធននិវត្តន៍ [illegible]

៣-រយៈពេលសុំបន្តការងារ មិនលើសពី ៥ឆ្នាំទៀត ។

## ជំពូកទី៣

## របបសោធនបាត់បង់សមត្ថភាពការងារ

មាត្រា១២.-

យោធិនអាជីព ដែលអាចទទួលរបបបាត់បង់សមត្ថភាពការងារជាប្រចាំខែ លុះត្រាតែបានបំពេញតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី ២ មាត្រា ៩ និងមាត្រា ១២ នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

អំពីរបៀបគិតរយៈពេលបំពេញការងារ ព្រមទាំងការកំណត់តំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ពិត្រូវអនុវត្តតាមការកំណត់ ដូចមានចែងក្នុងជំពូកទី ២ មាត្រា ៧ នៃអនុក្រឹត្យនេះ ។

មាត្រា១៣.-

លក្ខខណ្ឌជាក់ស្តែងនៃការកំណត់ប្រភេទកម្រិតថ្នាក់បាត់បង់សមត្ថភាពការងារចំពោះយោធិនអាជីព ត្រូវបានកំណត់កម្រិតជាបីថ្នាក់ ៖

**ក-កម្រិតថ្នាក់ទី១ :**

គឺជាយោធិនអាជីព ដែលបានបំពេញការងារ នាំអោយខ្ទុះទ្រោមទាំងស្រុងនៃសរីរាង្គកាយសំខាន់ៗ ។ ជនបាត់បង់សមត្ថភាពការងារ ពុំអាចធ្វើការងារបំរើខ្លួនឯងបាន និងត្រូវការអោយអ្នកដទៃជួយជាអចិន្ត្រៃយ៍ ។ យោធិននេះទទួលបានកម្រិតថ្នាក់បាត់បង់សមត្ថភាពការងារ លើសពី ៨០ភាគរយ ។

**ខ-កម្រិតថ្នាក់ទី២ :**

គឺជាយោធិនអាជីព ដែលបានបំពេញការងារ នាំអោយមានការខ្ទុះទ្រោមធ្ងន់ ឬស្រាលនៃមុខងារសំខាន់ៗរបស់សរីរាង្គកាយ ។ ជនបាត់បង់សមត្ថភាពការងារ អាចប្រកបការងារបាននៅក្នុងករណីពិសេស សាមីជនអាចធានាបានដោយខ្លួនឯងនូវសេចក្តីត្រូវការរបស់ខ្លួនមួយផ្នែកក្នុងជីវភាពប្រចាំថ្ងៃ ដោយមិនចាំបាច់ពឹងផ្អែកជំនួយអចិន្ត្រៃយ៍ពីអ្នកដទៃឡើយ ។ យោធិននេះទទួលបានកម្រិតថ្នាក់បាត់បង់សមត្ថភាពការងារ លើសពី ៦០ភាគរយ ។

**គ-កម្រិតថ្នាក់ទី៣ :**

គឺជាយោធិនអាជីព ដែលអាចបំពេញការងារបាននៅក្នុងករណីដែលបានកំណត់ ដោយមិនចាំបាច់មានអ្នកដទៃជួយនៅក្នុងជីវភាពប្រចាំថ្ងៃឡើយ ។ យោធិននេះ ទទួលបានកម្រិតថ្នាក់បាត់បង់សមត្ថភាពការងារលើសពី ៤០ភាគរយ ។

លក្ខខណ្ឌលំអិតជាក់ស្តែង នៃការកំណត់លក្ខណៈបាត់បង់សមត្ថភាពការងារ របស់យោធិនអាជីពទាំងពីរភេទ តាមថ្នាក់នីមួយៗ ត្រូវបានកំណត់ដោយប្រកាសរួមអន្តរក្រសួង របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

មាត្រា១៤.-

ប្រាក់សោធនបាត់បង់សមត្ថភាពការងារ រួមមាន បៀវត្សរ៍មានន្តរសក្តិ ត្រូវបានបូកបន្ថែមជាមួយប្រាក់ឧបត្ថម្ភលើបៀវត្សរ៍មានន្តរសក្តិ បូកប្រាក់បុប្ផប្រចាំខែ បូកប្រាក់បំណាច់មុខងារ "បើមាន" បូកប្រាក់បំណាច់តំបន់ "បើមាន" ។

មាត្រា១៥.-

យោធិនអាជីព ដែលអាចទទួលរបបសោធនបាត់បង់សមត្ថភាពការងារប្រចាំខែបាន លុះត្រាតែបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី២ មាត្រា១២ និងមាត្រា១៣ នៃច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

ក្រៅពីរបបដែលបានបញ្ជាក់ក្នុងវាក្យខណ្ឌខាងលើ យោធិនអាជីពទាំងពីរភេទ អាចទទួលបាននូវរបបរួមនៅក្នុងបន្ទុកដែលរដ្ឋទទួលស្គាល់ ដូចនៅពេលបំរើការងារ ។

មាត្រា១៦.-

យោធិនអាជីព ដែលមិនមានគ្រប់លក្ខខណ្ឌទទួលរបបសោធនបាត់បង់សមត្ថភាពការងារ ត្រូវទទួលបានរបបចេញពីជួរ ដូចមានចែងក្នុងជំពូកទី២ មាត្រា១១ នៃច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

## ជំពូកទី៤
## សមត្ថកិច្ចនៃការគ្រប់គ្រង និងបើករបបសោធននិវត្តន៍
## និងរបបសោធនបាត់បង់សមត្ថភាពការងារ

មាត្រា១៧.-

សមត្ថកិច្ចនៃការសំរេចអោយបន្តការងារទៀត ឬសំរេចអោយចូលនិវត្តន៍បាន ដូចមានចែងក្នុងជំពូកទី ១ មាត្រា ៨ នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពល

ខេមរភូមិន្ទ ព្រមទាំងអោយទទួលសោធនបាត់បង់សមត្ថភាពការងារ ឬអោយចេញពីជួរ ត្រូវបានកំណត់ដូចខាងក្រោម ៖

១- ដោយព្រះរាជក្រឹត្យ សម្រាប់យោធិនអាជីពថ្នាក់ឧត្តមសេនីយ៍ និងឧត្តមនាវី ។

២- ដោយអនុក្រឹត្យ សម្រាប់យោធិនអាជីពថ្នាក់វរសេនីយ៍ឯក និងវរនាវីឯក ។

៣- ដោយប្រកាសរបស់ក្រសួងការពារជាតិ សម្រាប់យោធិនអាជីពចាប់ពីថ្នាក់វរសេនីយ៍ទោ និងវរនាវីទោចុះ ។

ដើម្បីអនុវត្តឱ្យបានល្អនិងមានប្រសិទ្ធភាព ក្រសួងការពារជាតិត្រូវធ្វើប្រកាស កំណត់អំពីរបៀបគណនាប្រាក់សោធននិវត្តន៍ ប្រាក់សោធនបាត់បង់សមត្ថភាពការងារ និងកំណត់អំពីគំរូបែបបទសំណុំលិខិត នៃការដាក់ឱ្យចូលនិវត្តន៍ ដាក់ឱ្យចូលបាត់បង់សមត្ថភាពការងារ និងដាក់ឱ្យចេញពីជួរ ព្រមទាំងគំរូបែបបទ នៃការស្នើសុំបន្តការងារ នៅពេលដល់អាយុចូលនិវត្តន៍ ។

## មាត្រា១៨.-

ជារៀងរាល់ឆ្នាំ ក្រសួងការពារជាតិត្រូវធ្វើបញ្ជីឈ្មោះ ភ្ជាប់ជាមួយតួលេខចំនួនទឹកប្រាក់យោធិនចូលនិវត្តន៍ យោធិនបាត់បង់សមត្ថភាពការងារ និងយោធិនចេញពីជួរ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីបំរុងថវិកាបើកផ្តល់ប្រាក់សោធននិវត្តន៍ សោធនបាត់បង់ សមត្ថភាពការងារ និងចេញពីជួរ ។

ក្រសួងការពារជាតិ មានភារកិច្ចបើកប្រាក់ឧបត្ថម្ភមួយលើកជូនដល់និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងយោធិនចេញពីជួរ បន្ទាប់មកត្រូវផ្ទេរទៅអោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ក្រោយពីទទួលបាននិវត្តជន ជនបាត់បង់សមត្ថភាពការងារពីក្រសួងការពារជាតិរួចមក ការគ្រប់គ្រង ការបើកផ្តល់របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារប្រចាំខែ និងការបើករបបធានារ៉ាប់រងសង្គម សំរាប់គ្រួសារ ក្រោយមរណភាពរបស់និវត្តជន ឬជនបាត់បង់សមត្ថភាពការងារ ជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រហូតដល់ពេលបញ្ចប់លទ្ធិសោធន ។

## មាត្រា១៩.-

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាជ្ញាធរមានសមត្ថកិច្ចពិនិត្យលទ្ធភាព ក្នុងការបណ្តុះបណ្តាល និងជួយរកការងារធ្វើអោយនិវត្តជន ជនបាត់បង់សមត្ថភាពការងារ និងអតីតយោធិនចេញពីជួរ ដែលមានលទ្ធភាពធ្វើការងារទៀតបាន ផ្អែកតាមសំណើ និងជំនាញរបស់សាមីខ្លួន ។

## មាត្រា២០.-

យោធិនបាត់បង់សមត្ថភាពការងារ ដែលគ្មានទីបង្អែកដូចមានចែងក្នុងចំណុចទី ២មាត្រា ១៣ (ចំណុច២) នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ -រដ្ឋទទួលបន្ទុកយកទៅស្នាក់នៅមជ្ឈមណ្ឌលរបស់រដ្ឋ ឬនិវត្តជនចាស់ជរារស់នៅតែលតោលគ្មានទីបង្អែក ក៏មានសិទ្ធិដូចជន

បាត់បង់សមត្ថភាពដែរ ។

ចំពោះប្រាក់សោធននិវត្តន៍ ឬសោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ត្រូវកាត់យកស្មើនឹង ៥០ភាគរយ ដើម្បីជាអាករប្រមូលផ្តុំ បើសិនជាខ្វះខាត ផ្តល់ពេញបន្ថែម ។ ចំពោះយោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី១ បើសិនទៅរស់នៅមជ្ឈមណ្ឌលរបស់រដ្ឋ ប្រាក់ឧបត្ថម្ភសំរាប់អ្នកជំនួយកិច្ចការក្នុងផ្ទះមិនបានបើកផ្តល់អោយឡើយ ។

**មាត្រា២១.-**

និវត្តជន ឬជនបាត់បង់សមត្ថភាពការងារ មានសិទ្ធិស្នើសុំកាត់ឯកសណ្ឋានកងយោធពលខេមរភូមិន្ទ ដូចមានចែងក្នុងជំពូកទី ១ មាត្រា ៧ នៃច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ ដើម្បីជាកិត្តិយសក្នុងពិធីបុណ្យជាតិផ្សេងៗ ។

ការបើកផ្តល់ឯកសណ្ឋានកងយោធពលខេមរភូមិន្ទនេះ ត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

**មាត្រា២២.-**

ក្រោយពេលនិវត្តជន ឬជនបាត់បង់សមត្ថភាពការងារទទួលមរណភាព គ្រួសារទាំងនេះ ត្រូវបានប្រាក់ឧបត្ថម្ភ ដូចមានចែងក្នុងជំពូកទី២ មាត្រា១៤ នៃច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា២៣.-**

អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងអនុក្រឹត្យលេខ ៣២ អនក្រ.បក. ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០០០ ស្តីពីវិសោធនកម្មមាត្រា ១៤ និង១៥ នៃអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា២៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**ទៀ បាញ់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៨
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ: ០.៣៤/...

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៦

# ប្រកាស

## ស្តីពី

## ការណែនាំអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពនិងកីឡាករនៃកងយោធពលខេមរភូមិន្ទ

## រដ្ឋមន្ត្រីក្រសួងការពារជាតិ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពី ការកែសម្រួល តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពី ការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

ដើម្បីធានាអោយការអនុវត្តន៍បានត្រឹមត្រូវ និងមានប្រសិទ្ធភាពចំពោះផលប្រយោជន៍ពាក់ព័ន្ធទៅនឹងអតីតភាពការងាររបស់យោធិនគ្រប់រូប ។

## សម្រេច

## ជំពូកទី១

## ការកំណត់ទូទៅ

ប្រការ១.-

ប្រកាសនេះមានគោលដៅកំណត់ធ្វើការណែនាំលំអិត ក្នុងការអនុវត្តន៍របបសោធននិវត្តន៍ និងរបបសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ សំដៅអនុវត្តច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ព្រមទាំងអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពី ការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ។

ប្រការ២.-

ដើម្បីអនុវត្តប្រកាសនេះ ពាក្យខាងក្រោមត្រូវបានកំណត់និយមន័យដូចតទៅ ៖

-យោធិនអាជីព គឺជានាយទាហាន នាយទាហានរង ឬបុគ្គលិកសមាគម ដែលត្រូវបានទទួលអោយចូលជាយោធិនអាជីព ក្រោយពីបានធ្វើពាក្យសុំចូល ហើយបានតែងតាំងឋានន្តរសក្តិតាមឋានានុក្រម ។

-របបសោធននិវត្តន៍ គឺជាគោលរបបគិតជាទឹកប្រាក់ ដែលយោធិនគ្រប់រូបត្រូវទទួលបាន ក្រោយពេលបញ្ចប់ការងារក្នុងកងយោធពលខេមរភូមិន្ទ ដោយផ្អែកទៅលើលក្ខខណ្ឌឋានន្តរសក្តិ អាយុ និងលក្ខខណ្ឌរយៈពេលបំពេញការងារ ។

-របបបាត់បង់សមត្ថភាពការងារ គឺជាគោលរបបគិតជាទឹកប្រាក់ ដែលយោធិនគ្រប់រូបត្រូវទទួលបាន ក្រោយពេលបញ្ចប់ការងារក្នុងកងយោធពលខេមរភូមិន្ទ អាស្រ័យដោយសកម្មភាពបំពេញការងាររបស់ខ្លួនកន្លងមកមានផលប៉ះពាល់សុខភាព ដែលមិនអាចបំពេញការងារទៀតបាន ហើយត្រូវដាក់ចូលក្នុងប្រភេទបាត់បង់សមត្ថភាពការងារ ។

-របបចេញពីជួរ គឺជាគោលរបបគិតជាទឹកប្រាក់ ដែលយោធិនគ្រប់រូបត្រូវទទួលបាន ក្រោយពេលបញ្ចប់ការងារនៅក្នុងកងយោធពលខេមរភូមិន្ទ ដែលមិនបានទទួលរបបសោធននិវត្តន៍ និងរបបបាត់បង់សមត្ថភាពការងារ ។

## ជំពូកទី២

## ការកំណត់ អំពីការដាក់អោយចូលនិវត្តន៍ និង របៀបគណនា

ប្រការ៣.-

យោធិនទាំងពីរភេទ ត្រូវដាក់អោយចូលនិវត្តន៍តាមការកំណត់ ដោយមានលក្ខខណ្ឌឋានន្តរសក្តិ និង លក្ខខណ្ឌអាយុ ដូចមានចែងខាងក្រោម ÷

ក-នាយទាហាន :

| | | |
|---|---|---|
| ១-ថ្នាក់វរសេនីយ៍ឯក | និងវរនាវីឯកឡើងទៅ | នៅពេលដល់អាយុ ៦០ឆ្នាំ |
| ២-ថ្នាក់វរសេនីយ៍ទោ | និងវរនាវីទោ | នៅពេលដល់អាយុ ៥៨ឆ្នាំ |
| ៣-ថ្នាក់វរសេនីយ៍ត្រី | និងវរនាវីត្រី | នៅពេលដល់អាយុ ៥៥ឆ្នាំ |
| ៤-ថ្នាក់អនុសេនីយ៍ឯក | និងអនុនាវីឯក | នៅពេលដល់អាយុ ៥៣ឆ្នាំ |
| ៥-ថ្នាក់អនុសេនីយ៍ទោ | និងអនុនាវីទោ | នៅពេលដល់អាយុ ៤៨ឆ្នាំ |
| ៦-ថ្នាក់អនុសេនីយ៍ត្រី | និងអនុនាវីត្រី | នៅពេលដល់អាយុ ៤៦ឆ្នាំ |
| ៧-ថ្នាក់នាយចំណង់ | និងនាយនាវីចំណង់ | នៅពេលដល់អាយុ ៤៣ឆ្នាំ |

ខ-នាយទាហានរង :

| | | |
|---|---|---|
| ១-ថ្នាក់ព្រិន្ទបាលឯក | និងនាយចក្របាលឯក | នៅពេលដល់អាយុ ៤២ឆ្នាំ |
| ២-ថ្នាក់ព្រិន្ទបាលទោ | និងនាយចក្របាលទោ | នៅពេលដល់អាយុ ៤១ឆ្នាំ |
| ៣-ថ្នាក់ពលបាលឯក | និងចក្របាលឯក | នៅពេលដល់អាយុ ៤០ឆ្នាំ |
| ៤-ថ្នាក់ពលបាលទោ | និងចក្របាលទោ | នៅពេលដល់អាយុ ៣៩ឆ្នាំ |
| ៥-ថ្នាក់ពលបាលត្រី | និងចក្របាលត្រី | នៅពេលដល់អាយុ ៣៨ឆ្នាំ |

ប្រការ៤.-

យោធិនទាំងពីរភេទ ត្រូវដាក់អោយចូលនិវត្តន៍បានមុនពេលកំណត់ ដោយមិនគិតពីលក្ខខណ្ឌឋានន្តរសក្តិ មិនគិតពីលក្ខខណ្ឌអាយុ សាមីយោធិនត្រូវធ្វើពាក្យស្នើសុំចូលនិវត្តន៍មុនពេលកំណត់ ដោយមានការឯកភាពទទួលស្គាល់តាមឋានានុក្រម មកក្រសួងការពារជាតិ ។

ប្រការ៥.-

ការកំណត់អំពី រយៈពេលបំរើការងារ :

ក-រយៈពេលបំរើការងារក្រុម :

រយៈពេលបំរើការងារក្រុម គឺជារយៈពេលដែលយោធិនទាំងពីរភេទ បានបំរើការងារកងទ័ពផង និងស៊ីវិលផង ឬបានបំរើកងទ័ពតាមរបបសង្គមនីមួយៗ ឬរួមនឹងរយៈពេលបំរើកងយោធពលខេមរភូមិន្ទបច្ចុប្បន្ន រហូតដល់ថ្ងៃចូលនិវត្តន៍ ។

ដោយឡែក ចំពោះអ្នកដែលធ្លាប់បានបំរើការងាររដ្ឋមុនឆ្នាំ១៩៧៥ ហើយពុំបានបំរើការងារក្នុងរបបប៉ុល ពត ក៏ត្រូវបានគិតបន្ថែមរយៈពេលបំរើការងារ ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ ថែមទៀតដែរ ។

ខ-រយៈពេលបំរើការងារបន្តបន្ទាប់ ឬជាប់រហូត :

-រយៈពេលបំរើការងារបន្តបន្ទាប់ គឺគិតចាប់ពីថ្ងៃដែលយោធិនបានចូលបំរើក្នុងជួរកងទ័ព រហូតបង្កើតបានជាកងយោធពលខេមរភូមិន្ទ ដល់ថ្ងៃចូលនិវត្តន៍ ។

-ក្នុងចន្លោះពេលទៅសម្រាកច្បាប់ ព្យាបាលរោគ ទៅរៀនសូត្រក្នុង ឬក្រៅប្រទេស ដោយមានការចាត់តាំង រយៈពេលជាប់មន្ទីរឃុំឃាំងដោយគ្មានទោសកំហុស រយៈពេលជាប់ជាឈ្លើយសឹកខ្មាំង ដោយរក្សាបាននូវការសម្ងាត់ និងស្មោះត្រង់ចំពោះប្រទេសជាតិ ត្រូវបានគិតជារយៈពេលបំរើការងារជាប់រហូត ។

គ-រយៈពេលបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព :

-តំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព លុះត្រាតែបានបំរើការងារនោះជាប់រហូត ហើយបានបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម :

-រយៈពេលបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពស៊ីវិល "បើមាន" ត្រូវបានគិតរួមជាមួយរយៈពេលបន្តការងារតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ក្នុងកងយោធពលខេមរភូមិន្ទ ។

-ក្នុងចន្លោះពេលទៅសម្រាកច្បាប់ ទៅរៀនសូត្រ ឬទៅព្យាបាលរោគ (រយៈពេលពី ៦ខែចុះ) ក៏ត្រូវចាត់ទុកជារយៈពេលប៉ះពាល់សុខភាពជាប់រហូតដែរ ។

ឃ-រយៈពេលបំរើការងារអតីតកាល :

ការគិតរយៈពេលបំរើការងារអតីតភាពតាមរបបសង្គមនីមួយៗ និងការគិតអតីតភាព គិតចាប់តាំងពីពេលមានចលនាតស៊ូ រហូតដល់ថ្ងៃបង្កើតអង្គការមួយជាផ្លូវការ ហើយបានចូលរួមក្នុងរាជរដ្ឋាភិបាលរហូតដល់បច្ចុប្បន្ននេះ គិតស្មើនឹងរយៈពេលបំរើការងារក្នុងកងយោធពលខេមរភូមិន្ទ ។

ប្រការ៦.-

របៀបគណនារបបសោធននិវត្តន៍ :

ក-របបអាទិភាព :

-យោធិនទាំងពីរភេទ ដែលបានបំពេញការងារកងទ័ពមុនថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ជាប់រហូតដល់ថ្ងៃចូលនិវត្តន៍ ឬវីរជនដែលមានគ្រប់លក្ខខណ្ឌចូលនិវត្តន៍ ត្រូវបានទទួលរបបអាទិភាព ២០ភាគរយ នៃប្រាក់បៀវត្សរ៍ឋានន្តរសក្តិថែមទៀត ។

-យោធិនទាំងពីរភេទ ដែលបានបំពេញការងារកងទ័ពមុនថ្ងៃទី០៧ មករា ឆ្នាំ១៩៧៩ ជាប់រហូតដល់ថ្ងៃចូលនិវត្តន៍ ឬបានបំពេញការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ត្រូវបានទទួលរបបអាទិភាព ១៥ភាគរយ នៃប្រាក់បៀវត្សរ៍ឋានន្តរសក្តិថែមទៀត ។

របបអាទិភាពដូចមានរៀបរាប់ខាងលើនេះ និវត្តជនត្រូវបានរបបអាទិភាពណាមួយដែលខ្ពស់ជាងគេ មិនអាចទទួលបានទាំងពីរ ឬទាំងពីរនេះឡើយ ។

ខ-របបសោធននិវត្តន៍អប្បបរមា :

យោធិនទាំងពីរភេទ ដែលត្រូវបានទទួលរបបសោធននិវត្តន៍អប្បបរមាគឺ :

-យោធិនដែលបានដាក់អោយចូលនិវត្តន៍តាមការកំណត់ និងយោធិនដែលបានដាក់អោយចូលនិវត្តន៍មុនពេលកំណត់ ត្រូវមានរយៈពេលបំពេញការងារក្នុងកងទ័ពជាប់រហូតនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព យ៉ាងតិច ១០ (ដប់) ឆ្នាំ ចំពោះបុរស និងយ៉ាងតិច ៨ (ប្រាំបី) ឆ្នាំ ចំពោះនារី ។ ចំពោះយោធិនដែលបំពេញការងារមិនប៉ះពាល់សុខភាព ឬគ្រោះថ្នាក់ផ្សេងៗ ត្រូវមានរយៈពេលបំពេញការងារសរុប ២០ (ម្ភៃ) ឆ្នាំ ចំពោះបុរស និង ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះនារី ។

-ប្រាក់សោធននិវត្តន៍អប្បបរមាប្រចាំខែ ស្មើ ៥០ ភាគរយ នៃប្រាក់បៀវត្សរ៍ឋានន្តរសក្តិប្រចាំខែចុងក្រោយ ។ ប្រាក់នេះ ត្រូវបានអត្រាបន្ថែមមួយឆ្នាំ ២ ភាគរយទៀត រាប់ចាប់ពីឆ្នាំទី ៤ នៃរយៈពេលបំពេញការងារកងទ័ព ឬចាប់ពីឆ្នាំទី ៦ នៃរយៈពេលបំពេញការងាររដ្ឋ តែសរុបមិនត្រូវលើស ៨០ ភាគរយ នៃប្រាក់សោធននិវត្តន៍អតិបរមាឡើយ ។

គ-របបសោធននិវត្តន៍អតិបរមា :

-យោធិនទាំងពីរភេទ ដែលត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមា ជាយោធិនដែលដាក់អោយចូលនិវត្តន៍តាមការកំណត់ ត្រូវមានរយៈពេលបំពេញការងារក្នុងកងទ័ពជាប់រហូតនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ការងារប៉ះពាល់សុខភាព យ៉ាងតិច ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបុរស និងយ៉ាងតិច ១២ (ដប់ពីរ) ឆ្នាំ ចំពោះនារី ។ ចំពោះយោធិនដែលបំពេញការងារមិនប៉ះពាល់ សុខភាព ឬគ្រោះថ្នាក់ផ្សេងៗ ត្រូវមានរយៈពេលបំពេញការងារសរុប លើសពី ២០ (ម្ភៃ) ឆ្នាំ ចំពោះបុរស និង លើសពី ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះនារី ។

-ចំពោះឧត្តមសេនីយ៍ ឧត្តមនាវី ឬវីរជនក្នុងកងយោធពលខេមរភូមិន្ទ ដែលមានលក្ខខណ្ឌទទួលរបបសោធននិវត្តន៍អប្បបរមា ឬយោធិនពិការបំពេញការងារជាប់រហូតដល់អាយុចូលនិវត្តន៍ ត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមា ។

ប្រាក់សោធននិវត្តន៍អប្បបរមា ឬប្រាក់សោធននិវត្តន៍អតិបរមាខាងលើនេះ មិនអាចតិចជាងប្រាក់បៀវត្សរ៍ ឋានន្តរស័ក្តិអប្បបរមាប្រចាំខែរបស់នាយទាហានឡើយ ក្នុងករណីខាងជាង ត្រូវតម្លើងអោយស្មើ ។

ឃ-ក្រៅពីទទួលរបបឧបត្ថម្ភម្តង១ លោកនិងទាំងពីរភេទនៅបានទទួលប្រាក់ឧបត្ថម្ភមួយលើក ស្មើនឹង ៨ខែ នៃប្រាក់បៀវត្សរ៍ប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

ង-លោកនិងទាំងពីរភេទ ដោយពុំបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងចំណុច (ខ) (គ) ខាងលើនេះ នឹងមិន ផ្តល់របបសោធននិវត្តន៍ឡើយ ករណីនេះ រដ្ឋឧបត្ថម្ភប្រាក់មួយលើកគត់ ស្មើនឹងបៀវត្សរ៍សរុបចុងក្រោយរបស់ សាមីខ្លួន គុណនឹងចំនួនឆ្នាំនៃរយៈពេលបំពេញការងារ ប៉ុន្តែប្រាក់នេះ មិនត្រូវតិចជាងប្រាក់បៀវត្សរ៍ ៦ខែ របស់សាមី ខ្លួនឡើយ ។

ច-រូបមន្តគណនាប្រាក់សោធននិវត្តន៍ :

| ស.ន | = (ប + ឧ + ម + ព + ម្ហូប) × % |
|---|---|

| | |
|---|---|
| ស.ន | = ប្រាក់សោធននិវត្តន៍ប្រចាំខែ |
| ប | = ប្រាក់បៀវត្សរ៍ឋានន្តរស័ក្តិ |
| ឧ | = ប្រាក់ឧបត្ថម្ភលើបៀវត្សរ៍ឋានន្តរស័ក្តិ |
| ម | = ប្រាក់បំណាច់មុខងារ (បើមាន) |
| ព | = ប្រាក់បំណាច់តំបន់ (បើមាន) |
| ម្ហូប | = ប្រាក់ម្ហូប (មិនគិតបញ្ចូលថ្លៃអង្ករ) |
| % | = ចំនួនភាគរយ |

ប្រាក់បៀវត្សរ៍ឋានន្តរស័ក្តិអប្បបរមារបស់នាយទាហាន ត្រូវបានបូកជាមួយប្រាក់ឧបត្ថម្ភ ៥០ ភាគរយ លើប្រាក់បៀវត្សរ៍ឋានន្តរស័ក្តិ និងបូកជាមួយប្រាក់ម្ហូបបន្ថែមទៀត ។

ក្រៅពីរបបសោធននិវត្តន៍ដូចរៀបរាប់ខាងលើ នៅបានទទួលរបបផ្សេងៗទៀត មានដូចខាងក្រោម ÷

-ប្រាក់អាទិភាព

-ប្រាក់ឧបត្ថម្ភគ្រួសារ និង ប្រាក់ឧបត្ថម្ភកូន ។

ឆ-ឧទាហរណ៍ជាក់ស្តែង :

**ឧទាហរណ៍ទី១ :** លោកអនុសេនីយ៍ទោនៃកងទ័ពជើងគោកម្នាក់ មានអាយុ ៤៥ឆ្នាំ មានរយៈពេលបំពេញ ការងារបំពេញសុខភាពក្នុងកងទ័ព ចំនួន ១០ឆ្នាំ មានកូន ២នាក់ ។ លោកត្រូវបានចូលនិវត្តន៍មុនពេលកំណត់ និង បានទទួលរបបសោធននិវត្តន៍អប្បបរមា ។

-ប្រាក់បៀវត្សរ៍ឋានន្តរស័ក្តិ = ៤០.៤០០៛

-ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[៤០.៤០០៛ + \left(\frac{៤០.៤០០៛ \times ៥០}{១០០}\right) + ៤៥.០០០៛\right] = ១២១.៧៦០៛$$

-អត្រាបន្ថែម ២%

២% × ៧ំ = ១៤%

៥០% + ១៤% = ៦៤%

-ប្រាក់សោធននិវត្តន៍ផ្ទាល់ខ្លួន :

$$\frac{១២១.៧៦០៛ \times ៦៤}{១០០} = ៧៧.៩២៦,៤៛$$

-ប្រាក់នេះ តិចជាងប្រាក់អប្បបរមារបស់នាយទាហាន ដូច្នេះ លោកអនុសេនីយ៍ទោ ត្រូវទទួលប្រាក់បៀវត្សរ៍ឋានន្តរសក្តិអប្បបរមារបស់នាយទាហានវិញ :

$$\left[៣២.៤០០៛ + \left(\frac{៣២.៤០០៛ \times ៥០}{១០០}\right) + ៤៥\ ០០០៛\right] = ១០៦.៩៦០៛$$

| | | |
|---|---|---|
| -ប្រាក់អាទិភាព ១៥% | = | ៦.០៦០៛ |
| -ប្រាក់ឧបត្ថម្ភគ្រួសារ | = | ៣.០០០៛ |
| -ប្រាក់ឧបត្ថម្ភកូន | = | ៥.០០០៛ |
| * ប្រាក់សោធននិវត្តន៍ប្រចាំខែ | = | ១២០.៦២០៛ |

**ឧទាហរណ៍ទី២ :** លោកអនុសេនីយ៍ឯកម្នាក់ មានអាយុ ៥៥ឆ្នាំ មានរយៈពេលបំរើការងាររួម ២១ឆ្នាំ ក្នុងនោះ ស៊ីវិល ១៦ឆ្នាំ និងកងទ័ព ៥ឆ្នាំ មានកូន ២នាក់ ។

លោកត្រូវបានចូលនិវត្តន៍តាមការកំណត់ និងត្រូវបានទទួលបានសោធននិវត្តន៍អប្បបរមា :

-ប្រាក់បៀវត្សរ៍ឋានន្តរសក្តិ = ៤៤.៤០០៛

* ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[៤៤.៤០០៛ + \left(\frac{៤៤.៤០០៛ \times ៥០}{១០០}\right) + ៤៥.០០០៛\right] = ១២៩.៣៦០៛$$

-អត្រាបន្ថែម ២% :

+ស៊ីវិល = ២% × ១១ = ២២%

+កងទ័ព = ២% × ២ = ៤%

+សរុប = ២៦%

-ប្រាក់សោធននិវត្តន៍អប្បបរមា = ៥០% + ២៦% = ៧៦%

-ប្រាក់សោធននិវត្តន៍ផ្ទាល់ខ្លួន :

$$\frac{១២៩.៣៦០៛ \times ៧៦}{១០០} = ៩៨.៣១៣៛$$

-ប្រាក់នេះ តិចជាងប្រាក់អប្បបរមារបស់នាយទាហាន ដូច្នេះ លោកអនុសេនីយ៍ឯកត្រូវមកទទួលបៀវត្សរ៍ឋានន្តរសក្តិអប្បបរមារបស់នាយទាហានវិញ ។

$$\left[៣២.៤០០៛ + \left(\frac{៣២.៤០០៛ \times ៩០}{១០០}\right) + ៤៥.០០០៛\right] = ១០៦.៥៦០៛$$

| | | |
|---|---|---|
| -ប្រាក់ឧបត្ថម្ភគ្រួសារ | = | ៣.០០០៛ |
| -ប្រាក់ឧបត្ថម្ភកូន | = | ៥.០០០៛ |
| * ប្រាក់សោធននិវត្តន៍ប្រចាំខែ | = | ១១៤.៥៦០៛ |

**ឧទាហរណ៍ទី៣ :** វរសេនីយ៍ទោម្នាក់ មានអាយុ ៥៨ឆ្នាំ មានរយៈពេលបំរើការងារកងទ័ពជាប់រហូតដល់ថ្ងៃចូលនិវត្តន៍បានចំនួន ២៩ឆ្នាំ ក្នុងនោះ ចូលបំរើកងទ័ពមុនឆ្នាំ១៩៧០ បាន ៥ឆ្នាំ លោកបានរត់ទៅតស៊ូក្នុងព្រៃបាន ៩ឆ្នាំ និងបានចូលបំរើកងទ័ពរហូតដល់ថ្ងៃចូលនិវត្តន៍បាន ១៥ឆ្នាំទៀត ។ លោកមានកូន ៣នាក់ ។

លោកត្រូវបានចូលនិវត្តន៍តាមការកំណត់ និងត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមា :

-ប្រាក់បៀវត្សរ៍ឋានន្តរសក្តិ = ៥៨.៥០០៛

* ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[៥៨.៥០០៛ + \left(\frac{៥៨.៥០០៛ \times ៩០}{១០០}\right) + ៤៥.០០០៛\right] = ១៥៦.១៥០៛$$

-ប្រាក់សោធននិវត្តន៍ផ្ទាល់ខ្លួន :

$$\frac{១៥៦.១៥០៛ \times ៨០}{១០០} = ១២៤.៩២០៛$$

| | | |
|---|---|---|
| -ប្រាក់អាទិភាព (មុនឆ្នាំ១៩៧០) ២០% | = | ១១.៧០០៛ |
| -ប្រាក់ឧបត្ថម្ភគ្រួសារ | = | ៣.០០០៛ |
| -ប្រាក់ឧបត្ថម្ភកូន | = | ៧.៥០០៛ |
| * ប្រាក់សោធននិវត្តន៍ប្រចាំខែ | = | ១៤៧.១២០៛ |

**ឧទាហរណ៍ទី៤ :** លោកអនុសេនីយ៍ត្រីម្នាក់ មានអាយុ ៤៦ឆ្នាំ មានរយៈពេលបំរើការងារប៉ះពាល់សុខភាពក្នុងកងទ័ពជាប់រហូត ចំនួន ១៥ឆ្នាំ ។ លោកមានកូន ចំនួន ៣នាក់ លោកត្រូវបានចូលនិវត្តន៍តាមការកំណត់ និងត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមា :

-ប្រាក់បៀវត្សរ៍ឋានន្តរសក្តិ = ៣៦.៤០០៛

* ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[៣៦.៤០០៛ + \left(\frac{៣៦.៤០០៛ \times ៩០}{១០០}\right) + ៤៥.០០០៛\right] = ១១៤.១៦០៛$$

-ប្រាក់សោធននិវត្តន៍អតិបរមា :

$$\frac{១១៤.១៦០៛ \times ៨០}{១០០} = ៩១.៣២៨៛$$

-ប្រាក់នេះតិចជាងប្រាក់អប្បបរមារបស់នាយទាហាន ដូច្នេះ លោកអនុសេនីយ៍ត្រី ត្រូវមកទទួលប្រាក់បៀវត្សរ៍ឋានន្តរសក្តិអប្បបរមារបស់នាយទាហានវិញ :

$$\left[៣២.៤០០៛ + \left(\frac{៣២.៤០០៛ \times ៩០}{១០០}\right) + ៤៥.០០០៛\right] = ១០៦.៥៦០៛$$

| | | |
|---|---|---|
| -ប្រាក់អាទិភាព ១៥% | = | ៥.៤៦០៛ |
| -ប្រាក់ឧបត្ថម្ភគ្រួសារ | = | ៣.០០០៛ |
| -ប្រាក់ឧបត្ថម្ភកូន | = | ៧.៥០០៛ |
| * ប្រាក់សោធននិវត្តន៍ប្រចាំខែ | = | ១២២.៥២០៛ |

**ឧទាហរណ៍ទី៥** : លោកពលបាលឯកម្នាក់ មានអាយុ **៤២ឆ្នាំ មានរយៈ**ពេលបំរើការងារក្នុងកងទ័ព ២០ឆ្នាំ មានកូន ២នាក់ ។

លោកត្រូវបានចូលនិវត្តន៍តាមការកំណត់ ហើយត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមា :

-ប្រាក់បៀវត្សរ៍ឋានន្តរសក្តិ =២៦.៤០០៛

* ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[២៦.៤០០៛ + \left(\frac{២៦.៤០០៛ \times ៩០}{១០០}\right) + ៤៥.០០០៛\right] = ៩៥.១៦០៛$$

-ប្រាក់សោធននិវត្តន៍អតិបរមា

$$\frac{៩៥.១៦០៛ \times ៨០}{១០០} = ៧៦.១២៨៛$$

-ប្រាក់នេះ តិចជាងប្រាក់អប្បបរមារបស់នាយទាហាន ដូច្នេះ លោកពលបាលឯក ត្រូវមកទទួលប្រាក់បៀវត្សរ៍ឋានន្តរសក្តិអប្បបរមារបស់នាយទាហានវិញ :

$$\left[៣២.៤០០៛ + \left(\frac{៣២.៤០០៛ \times ៩០}{១០០}\right) + ៤៥.០០០៛\right] = ១០៦.៥៦០៛$$

-ប្រាក់ឧបត្ថម្ភគ្រួសារ = ៣.០០០៛

-ប្រាក់ឧបត្ថម្ភកូន = ៩.០០០៛

* ប្រាក់សោធននិវត្តន៍ប្រចាំខែ = ១១៤.៥៦០៛

## ជំពូកទី៣

## ការកំណត់ អំពីការដាក់អោយទទួលបាត់បង់សមត្ថភាពការងារ និង របៀបគណនា

ប្រការ៧.-

យោធិនទាំងពីរភេទ ដែលត្រូវទទួលបាត់បង់សមត្ថភាពការងារ លុះត្រាតែបានបំពេញលក្ខខណ្ឌ ដូចខាងក្រោម ÷

**ក-ការកំណត់អំពី ការដាក់អោយទទួលបាត់បង់សមត្ថភាពការងារ ដោយមិនស្ថិតក្នុងការកិច្ច :**

គឺជាយោធិនចាស់ជរា មានជម្ងឺរ៉ាំរ៉ៃ ឬទទួលគ្រោះថ្នាក់ផ្សេងៗ តែមិនបាត់បង់សរីរាង្គណាមួយ ហើយមិនគ្រប់លក្ខណៈជាយោធិនពិការ លុះត្រាតែបានបំរើការងាររដ្ឋរួម យ៉ាងតិច ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបុរស និងយ៉ាងតិច ១០ (ដប់) ឆ្នាំ ចំពោះនារី ។ រយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំ និង ១០ (ដប់) ឆ្នាំ ខាងលើនេះ ត្រូវមានរយៈពេលបំរើការងារក្នុងកងយោធពលខេមរភូមិន្ទ យ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ជាបន្តបន្ទាប់ មុនពេលទទួលបាត់បង់សមត្ថភាពការងារ ។

-រយៈពេលបំរើការងារ ត្រូវបានកំណត់ដូចមានចែងក្នុងជំពូកទី២ ប្រការ៥ នៃប្រកាសនេះ ។

**ខ-ការកំណត់អំពី ការដាក់អោយទទួលបាត់បង់សមត្ថភាពការងារ ដោយសារការកិច្ច :**

គឺជាយោធិនដែលបានបំពេញការកិច្ច ឬធ្វើការនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ដោយពុំគិតពីអាយុ ឬរយៈពេលបំរើការងាររដ្ឋរួមឡើយ ហើយត្រូវបានទទួលបាត់បង់សមត្ថភាពការងារតាមការកំណត់កំរិតបាត់បង់សមត្ថភាពការងារជាបីថ្នាក់ ដូចខាងក្រោម :

-ថ្នាក់ទី១ បាត់បង់សមត្ថភាពការងារលើសពី ៨០ ភាគរយ

-ថ្នាក់ទី២ បាត់បង់សមត្ថភាពការងារលើសពី ៦០ ភាគរយ

-ថ្នាក់ទី៣ បាត់បង់សមត្ថភាពការងារលើសពី ៤០ ភាគរយ

លក្ខខណ្ឌនៃការកំណត់កំរិតថ្នាក់បាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទ ត្រូវបានកំណត់ដូចមានចែងក្នុងជំពូកទី៣ មាត្រាទី១៣ នៃអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ។

គ-យោធិនទាំងពីរភេទ ដែលបានដាក់អោយទទួលបាត់បង់សមត្ថភាពការងារ ដូចមានចែងក្នុងចំណុច (ក) (ខ) ខាងលើ ត្រូវបានទទួលរបបសោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ចែកជាពីរថ្នាក់ដូចខាងក្រោម ÷

១-របបសោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ស្មើនឹង ៥០ ភាគរយ នៃបៀវត្សរ៍តាមឋានន្តរសក្តិ ចុងក្រោយ ត្រូវបានផ្តល់ចំពោះ ÷

-យោធិនដែលបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងចំណុច (ក) ខាងលើ

-យោធិនដែលបានបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ត្រូវមានរយៈពេលបំរើការងារចំនួន ១០ (ដប់) ឆ្នាំ ចំពោះបុរស និង ៨ (ប្រាំបី) ឆ្នាំ ចំពោះនារី ។

ប្រាក់សោធនបាត់បង់សមត្ថភាពការងារអប្បបរមាប្រចាំខែស្មើ ៥០ ភាគរយ នៃបៀវត្សរ៍ឋានន្តរសក្តិប្រចាំខែចុងក្រោយ ត្រូវបានអត្រាបន្ថែមមួយឆ្នាំ ១.៥ ភាគរយទៀត រាប់ចាប់ពីឆ្នាំទី ៥ នៃរយៈពេល បំរើការងារកងទ័ព ឬចាប់ពីឆ្នាំទី ៦ នៃរយៈពេលបំរើការងាររដ្ឋរម ។ តែប្រាក់សរុបមិនត្រូវលើស ៦០ ភាគរយ នៃប្រាក់សោធនបាត់បង់សមត្ថភាពការងារឡើយ ។

**២-ប្រាក់សោធនបាត់បង់សមត្ថភាពការងារ :**

-យោធិនបាត់បង់សមត្ថភាពការងារកំរិតថ្នាក់ទី១ ទទួលបាន ១០០ ភាគរយ នៃបៀវត្សរ៍ឋានន្តរសក្តិប្រចាំខែចុងក្រោយរបស់សាមីខ្លួន និងត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែបន្ថែមសម្រាប់អ្នកជំនួយកិច្ចការក្នុងផ្ទះ ស្មើនឹងប្រាក់បៀវត្សរ៍ប្រចាំខែយុទ្ធជនម្នាក់ ។

-យោធិនបាត់បង់សមត្ថភាពការងារកំរិតថ្នាក់ទី២ ទទួលបាន ៨០ ភាគរយ នៃបៀវត្សរ៍ឋានន្តរសក្តិប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

-យោធិនបាត់បង់សមត្ថភាពការងារកំរិតថ្នាក់ទី៣ ទទួលបាន ៦០ ភាគរយ នៃបៀវត្សរ៍ឋានន្តរសក្តិប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

-ប្រាក់សោធនបាត់បង់សមត្ថភាពការងារទាបបំផុត មិនត្រូវតិចជាង ៥០ ភាគរយ នៃបៀវត្សរ៍ឋានន្តរសក្តិអប្បបរមារបស់នាយទាហានឡើយ ក្នុងករណីទាបជាង ត្រូវតម្លើងអោយស្មើ ។

-យោធិនដែលធ្វើការនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ត្រូវបានអត្រាបន្ថែម ១៥ ភាគរយ នៃបៀវត្សរ៍ឋានន្តរសក្តិថែមទៀត ។

-ចំពោះវីរជននៃកងយោធពលខេមរភូមិន្ទ ត្រូវបានទទួលអត្រាបន្ថែម ១០ ភាគរយ នៃបៀវត្សរ៍ឋានន្តរសក្តិថែមទៀត ។

ឃ-ក្រោយពីដាក់អោយទទួលបាត់បង់សមត្ថភាពការងារ យោធិនទាំងពីរភេទ នៅបានទទួលប្រាក់ឧបត្ថម្ភមួយលើក ស្មើនឹង ៦ខែ នៃបៀវត្សរ៍ឋានន្តរសក្តិចុងក្រោយរបស់សាមីខ្លួនបន្ថែមទៀត ។

ង-យោធិនទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ដែលមិនបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុង ចំណុច (ក) (ខ) ខាងលើនេះ រដ្ឋមិនផ្តល់របបសោធនបាត់បង់សមត្ថភាពការងារទេ ឡើយ ។ ករណីនេះ រដ្ឋឧបត្ថម្ភប្រាក់មួយលើកគត់ ស្មើនឹងបៀវត្សរ៍ចុងក្រោយរបស់សាមីខ្លួន គុណនឹងចំនួនឆ្នាំដែលបានបំរើការងារ ប៉ុន្តែទឹកប្រាក់នេះមិនត្រូវតិចជាងប្រាក់បៀវត្សរ៍ ៦ខែ របស់សាមីខ្លួនឡើយ ។

ច-រូបមន្តគណនាប្រាក់សោធនបាត់បង់សមត្ថភាពការងារ :

| ស.ប = (ប + ឧ + ម + ត + ម្ហូប) × % |
|---|

ស.ប = ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ

ប = ប្រាក់បៀវត្សរ៍ហានិភ័យសន្តិ

ឧ = ប្រាក់ឧបត្ថម្ភលើបៀវត្សហានិភ័យសន្តិ

ម = ប្រាក់បំណាច់មុខងារ "បើមាន"

ត = ប្រាក់បំណាច់តំបន់ "បើមាន"

ម្ហូប = ប្រាក់ម្ហូប ( មិនគិតបញ្ចូលថ្លៃអង្ករ)

% = ចំនួនភាគរយ

ប្រាក់បៀវត្សរ៍ហានិភ័យសន្តិអប្បបរមារបស់នាយទាហាន ត្រូវបានបូកជាមួយប្រាក់ឧបត្ថម្ភលើប្រាក់បៀវត្សរ៍ហានិភ័យសន្តិ បូកប្រាក់បំណាច់មុខងារ ប្រាក់បំណាច់តំបន់ ប្រាក់បំណាច់ជំនាញ បូកនឹង ប្រាក់ម្ហូប ។ ក្រៅពីរបបបាត់បង់សមត្ថភាពការងារផ្ទាល់ខ្លួនខាងលើនេះ នៅបានទទួលរបបផ្សេងៗ ដូចខាងក្រោម :

-ប្រាក់អាទិភាព

-ប្រាក់ឧបត្ថម្ភគ្រួសារ និងប្រាក់ឧបត្ថម្ភកូន ។

ឆ-ឧទាហរណ៍ជាក់ស្តែង :

ឧទាហរណ៍ទី១ : លោកនាយចំណង់ម្នាក់ បានរងគ្រោះថ្នាក់ផ្ទាល់ខ្លួន មិនអាចបន្តការងារទៀតបាន ។ លោកមានរយៈពេលបំរើការងារសរុបចំនួន ១៥ឆ្នាំ ក្នុងនោះស៊ីវិល ១០ឆ្នាំ និងកងទ័ព ៥ឆ្នាំ ។ គាត់មានកូន ១នាក់ នៅក្នុងបន្ទុក ។

លោកត្រូវទទួលបាត់បង់សមត្ថភាពការងារ ដោយពុំមែនបំពេញភារកិច្ច នឹងត្រូវទទួលរបបសោធនបាត់បង់សមត្ថភាពការងារ ៥០% ។

-ប្រាក់បៀវត្សរ៍ហានិភ័យសន្តិ = ៣២.៤០០៛

* ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[៣២.៤០០៛ + \left(\frac{៣២.៤០០៛ \times ៥០}{១០០}\right) + ៤៥.០០០៛\right] = ១០៦.៥៦០៛$$

-អត្រាបន្ថែម ១.៥%

+ស៊ីវិល = ១.៥% × ៥ = ៧,៥%

+កងទ័ព = ១.៥% × ២ = ៣ %

* សរុប =១០.៥%

-ប្រាក់សោធនបាត់បង់សមត្ថភាពការងារផ្ទាល់ខ្លួន

៥០% + ១០.៥% = ៦០.៥%

ប្រាក់នេះ មិនត្រូវលើសពី ៦០%ឡើយ ដូច្នេះត្រូវទទួល ៦០%វិញ :

$$\frac{១០៦.៥៦០៛ \times ៦០}{១០០} = ៦៣.៩៣៦៛$$

ដូចនេះ ត្រូវមកទទួលប្រាក់ ៩០% នៃប្រៀវត្សរ៍មានន្តរសក្តិអប្បបរមារបស់នាយទាហានវិញ

$$\frac{១០៦.៥៦០៛ \times ៩០}{១០០} = ៩៥.៩០៤៛$$

-ប្រាក់ឧបត្ថម្ភប្រពន្ធ = ៣.០០០៛

-ប្រាក់ឧបត្ថម្ភកូន ១នាក់ = ២.៥០០៛

* ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ = **១០១.៤០៤៛**

ឧទាហរណ៍ទី២ : លោកវរសេនីយ៍ឯកម្នាក់ មានរយៈពេលបំរើការងារ ១៥ឆ្នាំ លោកបានទទួលរងគ្រោះថ្នាក់ក្រឡាប់រថយន្តដោយការងារផ្ទាល់ខ្លួន ហើយមិនអាចបំរើការងារបានទៀតឡើយ ។ គាត់មានកូន ២នាក់ ។

លោកត្រូវបានទទួលបាត់បង់សមត្ថភាពការងារកំរិតថ្នាក់ទី២ ។

លោកត្រូវទទួលរបបសោធនបាត់បង់សមត្ថភាពការងារ ៥០%

-ប្រាក់បៀវត្សរ៍មានន្តរសក្តិ = ៦៤.៥០០៛

* ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[៦៤.៥០០៛ + \left(\frac{៦៤.៥០០៛ \times ៩០}{១០០}\right) + ៤៥.០០០៛\right] = ១៦៧.៥៥០៛$$

-អត្រាបន្ថែម

១.៥% × ១២ = ១៨%

៥០% + ១៨% = ៦៨%

* ប្រាក់សោធនបាត់បង់សមត្ថភាពការងារផ្ទាល់ខ្លួន :

-ប្រាក់នេះ មិនត្រូវលើសពី ៦០% ទេ

$$\frac{១៦៧.៥៥០៛ \times ៦០}{១០០} = ១០០.៥៣០៛$$

-ប្រាក់ឧបត្ថម្ភប្រពន្ធ = ៣.០០០៛

-ប្រាក់ឧបត្ថម្ភកូន២នាក់ = ៥.០០០៛

* ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ = **១០៨.៥៣០៛**

ឧទាហរណ៍ទី៣ : លោកពលបាលត្រីម្នាក់ បំរើការងារនៅតំបន់សមរភូមិ ជាន់គ្រាប់មីនជាប់ហូតដល់មានជម្ងឺ មិនអាចបន្តការងារទៀតបាន ។

លោកត្រូវទទួលរបបសោធនបាត់បង់សមត្ថភាពការងារកំរិតថ្នាក់ទី២ ។

-ប្រាក់បៀវត្សរ៍ជាមធ្យមប្រចាំខែ = ២៤.៥០០៛

* ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[២៤.៥០០៛ + \left(\frac{២៤.៥០០៛ \times ៩០}{១០០}\right) + ៤៥.០០០៛\right] = ៩១.៥៥០៛$$

-ប្រាក់សោធនបាត់បង់សមត្ថភាពការងារផ្ទាល់ខ្លួន

$$\frac{៩១.៥៥០៛ \times ៦០}{១០០} = ៥៤.៩៣០៛$$

ដូច្នេះ ត្រូវមកទទួលប្រាក់ ៩០% នៃបៀវត្សរ៍ជាមធ្យមប្រចាំខែរបស់នាយទាហានវិញ :

$$\frac{១០៦.៥៦០៛ \times ៩០}{១០០} = ៩៥.៩០៤៛$$

-ប្រាក់អាទិភាព ១៥% = ៣.៦៧៥៛

-ប្រាក់ឧបត្ថម្ភគ្រួសារ = ៣.០០០៛

* ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ = **១០២.៥៧៩៛**

**ឧទាហរណ៍ទី៤ :** លោកវរសេនីយ៍ត្រីម្នាក់ បានរងគ្រោះថ្នាក់ក្នុងពេលបេសកកម្ម ។ លោកមានកូន ២នាក់ ។ លោកត្រូវទទួលបាត់បង់សមត្ថភាពការងារកំរិតថ្នាក់ទី១ ។

-ប្រាក់បៀវត្សរ៍ជាមធ្យមប្រចាំខែ = ៥៤.៥០០៛

-ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[៥៤.៥០០៛ + \left(\frac{៥៤.៥០០៛ \times ៩០}{១០០}\right) + ៩៥.០០០៛\right] = ១៩៨.៥៥០៛$$

| | | |
|---|---|---|
| +ប្រាក់អាទិភាព ១៥% | = | ៨.១៧៥៛ |
| +ប្រាក់ឧបត្ថម្ភគ្រួសារ | = | ៣.០០០៛ |
| +ប្រាក់ឧបត្ថម្ភកូន | = | ៥.០០០៛ |
| +ប្រាក់អ្នកជំនួយការងារម្នាក់ | = | ៣៦.៨០០៛ |
| * ប្រាក់សោធនបាត់បង់សមត្ថភាពការងារ | = | **២៥១.៥២៥៛** |

## ជំពូកទី៤

## ការកំណត់ នីតិវិធី និង គំរូបែបបទសំណុំលិខិត

**ប្រការ៨..**

នាយទាហាន នាយទាហានរង និងពលទាហាន ក្នុងកងយោធពលខេមរភូមិន្ទ ត្រូវបំពេញបែបបទស្តីពីជីវប្រវត្តិពិស្តារ តាមគំរូនៃ "ឧបសម្ព័ន្ធទី១" ។ ចំពោះការណែនាំលំអិតអំពីការសរសេរជីវប្រវត្តិពិស្តារនេះ នាយកដ្ឋានសោធននិវត្តន៍ នៃ អគ្គនាយកដ្ឋានយោធសេវា ជាអ្នកណែនាំផ្ទាល់ ។

ប្រការ៩.-

ជារៀងរាល់ឆ្នាំ ស្ថាប័នជំនាញ (នាយកដ្ឋានសោធននិវត្តន៍ នៃ អគ្គនាយកដ្ឋានយោធសេវា) ត្រូវស្រង់ឈ្មោះយោធិនទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ដែលត្រូវដាក់អោយចូលនិវត្តន៍តាមការកំណត់ និងត្រូវដាក់អោយចូលនិវត្តន៍មុនពេលកំណត់ ព្រមទាំងយោធិនដែលត្រូវទទួលបាត់បង់សមត្ថភាពការងារ និងយោធិនដែលត្រូវដាក់អោយចេញពីជួរ ស្របតាមផែនការប្រចាំឆ្នាំ ដើម្បីត្រៀមបំរុងមាន :

ក-ការស្នើសុំថវិកាឧបត្ថម្ភមួយលើក

ខ-ការស្នើសុំថវិកាធ្វើដំណើរ ហូបចុក ចំពោះអ្នកមានច្បាប់ឈប់សម្រាក

គ-ការធ្វើតំរោងប៉ាន់ស្មាន អំពីថវិកាប្រចាំខែ

ប្រការ១០.-

យោធិនទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ស្ថិតក្នុងមុខសញ្ញាសោធននិវត្តន៍ និងទទួលបានការជូនដំណឹងក្នុងរយៈពេល ១២ខែ ជាមុន ដើម្បីប្រុងប្រៀបកិច្ចការផ្សេងៗមាន :

ក-ការប្រុងប្រៀបជីវភាពរស់នៅក្នុងគ្រួសារ ក្រោយពេលចាកចេញពីកងយោធពលខេមរភូមិន្ទ ដោយអាចអនុញ្ញាតឈប់សម្រាកច្បាប់តាមការកំណត់ ដូចខាងក្រោម :

| | | |
|---|---|---|
| -ថ្នាក់ព្រិន្ទបាលឯកចុះ | ត្រូវបានឈប់សម្រាក | ៦ខែ |
| -ថ្នាក់នាយចំណង់ និងអនុសេនីយ៍ | ត្រូវបានឈប់សម្រាក | ៨ខែ |
| -ថ្នាក់វរសេនីយ៍ | ត្រូវបានឈប់សម្រាក | ១០ខែ |
| -ថ្នាក់ឧត្តមសេនីយ៍ ឬវីរជន | ត្រូវបានឈប់សម្រាក | ១២ខែ |

នៅពេលឈប់សម្រាកច្បាប់ក្នុងប្រទេស ត្រូវទទួលបានប្រាក់ធ្វើដំណើរ ប្រាក់ហូបចុកតាមផ្លូវ ទាំងទៅទាំងមក ។

ខ-ការបំពេញសំណុំលិខិតទទួលរបបសោធននិវត្តន៍ ។

គ-ការបំពេញបែបបទសុំបន្តការងារ ចំពោះយោធិនដែលមានវិន័យ គុណសម្បត្តិ សមត្ថភាព និងសុខភាពល្អ ឬជាអ្នកជំនាញឯកទេស ផ្អែកតាមតម្រូវការចាំបាច់របស់កងឯកភាព អាចស្នើសុំបន្តការងារមកក្រសួងការពារជាតិ ក្នុង ១ឆ្នាំម្តងៗ ។ រយៈពេលសុំបន្តការងារនេះ មិនត្រូវលើសពី ៥ឆ្នាំឡើយ ។

-រយៈពេលនៃការសុំបន្តការងារនេះ យោធិននៅទទួលបាន :

-សិទ្ធិទទួលបៀវត្សរ៍ ដូចក្នុងស្ថានភាពសកម្ម

-រយៈពេលបំពេញការងារបន្ត ត្រូវបានគិតក្នុងអតីតភាព ដើម្បីទទួលរបបសោធននិវត្តន៍អតិបរមា ឬអប្បបរមា ។

-ចំពោះការជូនដំណឹង គំរូបែបបទនៃការស្នើសុំឈប់សម្រាក ការបំពេញសំណុំលិខិតទទួលរបបសោធននិវត្តន៍ ការបំពេញសំណុំលិខិតទទួលរបបសោធនបាត់បង់សមត្ថភាពការងារ ការបំពេញសំណុំលិខិតទទួលរបបឧបត្ថម្ភចេញពីជួរ និងការបំពេញបែបបទសុំបន្តការងារ នោះនាយកដ្ឋានសោធននិវត្តន៍ នៃ អគ្គនាយកដ្ឋានយោធសេវា ជាអ្នកអនុវត្ត និងធ្វើការណែនាំលំអិតតាមគំរូនៃ "ឧបសម្ព័ន្ធទី២" ។

## ជំពូកទី៥
## ការគិតគូរ អន្តរសមត្ថកិច្ចពាក់ព័ន្ធ និង ការធានាផ្សេងៗ

ដោយរដ្ឋមិនទាន់អាចធានា ចំពោះការបង្កើតបេឡាសោធនរបស់កងទ័ពបាន ហេតុនេះ ក្នុងកាលៈទេសៈបណ្ដោះអាសន្ន ការធានាថវិកាឧបត្ថម្ភមួយលើក ការធានាថវិកាពេលឈប់សម្រាកច្បាប់ ត្រូវពឹងផ្អែកទៅលើការស្នើសុំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រីឯថវិកាប្រចាំខែ និងការគ្រប់គ្រង ចំពោះនិវត្តជន និងជនបាត់បង់សមត្ថភាពការងារ ត្រូវបានប្រគល់អោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គ្រប់គ្រងបន្តសិន ។

ដើម្បីមានមូលដ្ឋានអនុវត្តមុនពេលបង្កើតបេឡាសោធន ប្រការខាងក្រោមត្រូវបានចែង ៖

**ប្រការ១១.-**

ក្រសួងការពារជាតិ ធានាបើកផ្ដល់ប្រាក់ឧបត្ថម្ភមួយលើក ជូនដល់យោធិនស្ថិតក្នុងមុខសញ្ញាសោធននិវត្តន៍ និងមុខសញ្ញាបាត់បង់សមត្ថភាពការងារ មុនពេលផ្ទេរប្រគល់ការធានាបើកផ្ដល់បន្តទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមទាំងបើកប្រាក់ឧបត្ថម្ភមួយលើក ចំពោះមុខសញ្ញាយោធិនចេញពីជួរ មុនពេលចាកចេញពីកងយោធពលខេមរភូមិន្ទ និងបើកផ្ដល់ប្រាក់ធ្វើដំណើរ ហូបចុក ចំពោះយោធិនស្ថិតក្នុងមុខសញ្ញាសោធននិវត្តន៍ ដែលបានអនុញ្ញាតឈប់សម្រាកច្បាប់ ក្នុងរយៈពេលប្រុងប្រៀបជីវភាព ដូចមានចែងក្នុងប្រការ១០ ចំណុច (ក) នៃប្រកាសនេះ ។

**ប្រការ១២.-**

ដើម្បីធានាបានការផ្ទេរប្រគល់និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ព្រមទាំងធានាបានការប្រែប្រួលក្រោយពេលផ្ទេរប្រគល់ទៅអោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នាយកដ្ឋានសោធននិវត្តន៍ នៃ អគ្គនាយកដ្ឋានយោធសេវា ត្រូវធ្វើបែបបទនៃការផ្ទេរ និងបែបបទតាមដានការប្រែប្រួល ចំពោះនិវត្តជន និងជនបាត់បង់សមត្ថភាពការងារ សំដៅផ្សារភ្ជាប់ រហូតបង្កើតបានបេឡាសោធនរបស់កងទ័ព តាមគំរូបែបបទនៃ "ឧបសម្ព័ន្ធទី៣" ។

**ប្រការ១៣.-**

និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ដែលគ្មានគ្រួសារជាទីពឹងផ្អែក រដ្ឋទទួលបន្ទុកអោយស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ។

ប្រាក់សោធននប្រចាំខែ ត្រូវបានកាត់ស្មើ ៥០ ភាគរយ ដើម្បីធានាការហូបចុក បើខ្វះខាត រដ្ឋបំពេញបន្ថែម ។

ចំពោះយោធិនបាត់បង់សមត្ថភាពការងារកំរិតថ្នាក់ទី១ ប្រសិនបើទៅរស់នៅក្នុងមណ្ឌលចិញ្ចឹមរបស់រដ្ឋ ប្រាក់ឧបត្ថម្ភ សម្រាប់អ្នកបម្រើផ្ទាល់ រដ្ឋមិនបានបើកផ្តល់អោយឡើយ ។

**ប្រការ១៤.**

និវត្តជន និងជនបាត់បង់សមត្ថភាពការងារ មានសិទ្ធិស្លៀកពាក់ឯកសណ្ឋានកងយោធពលខេមរភូមិន្ទ ក្នុងពិធីបុណ្យជាតិផ្សេងៗ ។

## ជំពូកទី៦
## ការកំណត់បញ្ចប់

**ប្រការ១៥.**

រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៦.**

អគ្គលេខាធិការ ក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋាន នាយក នាយកដ្ឋាន ប្រធានស្ថាប័ន និងមេបញ្ជាការកងឯកភាពដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ទាហ៊ាន.ផ្កាយមាស៤ ទៀ-បាញ់

ចម្លងជូន
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ថ្នាក់ដឹកនាំក្រសួងការពារជាតិ
-ទីប្រឹក្សាក្រសួងការពារជាតិ
-អគ្គបញ្ជាការដ្ឋាន
-ដូចប្រការ១៦
(ដើម្បីជូនជ្រាប និងអនុវត្ត)
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ជីវប្រវត្តិពិស្តារ

## *នាយទាហាន នាយទាហានរង និងពលទាហាន*

- អត្តលេខ : ..................................................
- នាមត្រកូល : ......................... នាមខ្លួន: .........................
- ឈ្មោះជាអក្សរឡាតាំង : ..................................................
- ឈ្មោះកំណើត : ..................................................
- ឈ្មោះហៅក្រៅ : ................................ ភេទ: ..............
- ឋានន្តរសក្តិ : ..................................................
- មុខងារ : ..................................................
- អង្គភាព : ..................................................

លេខសំគាល់ ....................

អក្សរតម្កល់ ....................

## VI. [illegible] ស្ថានភាពគ្រួសារ អាណាព្យាបាល

-ឈ្មោះប្តី ឬ ប្រពន្ធ ឈ្មោះកូន ភេទ ថ្ងៃខែឆ្នាំកំណើត មុខរបរ ទីលំនៅបច្ចុប្បន្ន (បើនៅលីវ ត្រូវសរសេរឈ្មោះ ឪពុក ម្តាយបង្កើត ឬ អាណាព្យាបាល) ។

| ល.រ | ឈ្មោះប្តី ឬប្រពន្ធ និងកូន | ភេទ | ថ្ងៃ ខែ ឆ្នាំកំណើត | មុខរបរ | ភូមិ ឃុំ ស្រុក ខេត្ត |
|---|---|---|---|---|---|
| | | | | | |

* អាណាព្យាបាល

| ល.រ | ឈ្មោះ | ភេទ | ថ្ងៃ ខែ ឆ្នាំកំណើត | ត្រូវជា | ភូមិ ឃុំ ស្រុក ខេត្ត |
|---|---|---|---|---|---|
| | | | | | |
| | | | | | |

-ខ្ញុំបាទ-នាងខ្ញុំ សូមធានាអះអាងលើការបំពេញជីវប្រវត្តិនេះថា ពិតជាត្រឹមត្រូវប្រាកដមែន ។

លេខ......................

ធ្វើនៅថ្ងៃទី..........ខែ...............ឆ្នាំ២០០...

ធ្វើនៅថ្ងៃទី........ខែ.............ឆ្នាំ២០០...

មេបញ្ជាការកងឯកភាព    [illegible]    [illegible]    ហត្ថលេខា និង ស្នាមមេដៃសាមីខ្លួន

-*កំណត់សំគាល់* : *សរសេរអោយច្បាស់លាស់ ហាមកោសលុប* ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បណ្ណព័ត៌មានផ្ទាល់ខ្លួន

+នាមត្រកូល-នាមខ្លួន :..................................ជាអក្សរឡាតាំង :..................................

-ឈ្មោះដើម :..................................ភេទ :..............អត្តលេខ :..................................

-ថ្ងៃ ខែ ឆ្នាំកំណើត :..................................ថ្ងៃ ខែ ឆ្នាំចូលកងទ័ព :..................................

-ឋានន្តរសក្តិ :..................................មុខងារ :..................................

-ជំនាញឯកទេស :..................................កងឯកភាព :..................................

-ទីកន្លែងកំណើត :..................................................................................

-ទីលំនៅបច្ចុប្បន្ន :..................................................................................

..................................................................(ផ្អែកលើការបញ្ជាក់មូលដ្ឋាន) ។

+រយៈពេលបំរើការងារ :

-មុនថ្ងៃទី ១៨ មីនា ១៩៧០ : កងទ័ព :...............ឆ្នាំ. ស៊ីវិល :...............ឆ្នាំ. សរុប :...............ឆ្នាំ

..................................................................................................

-មុនថ្ងៃទី ១៧ មេសា ១៩៧៥: កងទ័ព :...............ឆ្នាំ. ស៊ីវិល :...............ឆ្នាំ. សរុប :...............ឆ្នាំ

..................................................................................................

-មុនថ្ងៃទី ០៧ មករា ១៩៧៩ : កងទ័ព :...............ឆ្នាំ. ស៊ីវិល :...............ឆ្នាំ. សរុប :...............ឆ្នាំ

..................................................................................................

-ក្រោយថ្ងៃទី ០៧ មករា ១៩៧៩ : កងទ័ព :...............ឆ្នាំ. ស៊ីវិល :...............ឆ្នាំ. សរុប :...............ឆ្នាំ

..................................................................................................

+រយៈពេលបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព :

..................................................................................................

..................................................................................................

ព័ត៌មានដែលខ្ញុំបាទ/នាងខ្ញុំ បានសរសេរផ្ទាល់ដៃខាងលើនេះ សន្យាថាត្រឹមត្រូវពិតប្រាកដមែន បើការសរសេរនេះ មិនត្រឹមត្រូវទេ ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់ ។

ធ្វើនៅថ្ងៃទី.........ខែ...............ឆ្នាំ២០០...

ហត្ថលេខា និង ស្នាមមេដៃស្តាំ

<u>បញ្ជាក់</u>

ដោយខ្ញុំបាទ/នាងខ្ញុំមិនចេះសរសេរ
ហេតុនេះ ខ្ញុំបាទ/នាងខ្ញុំបានពឹងពាក់
លោកឈ្មោះ.................................
ជាអ្នកសរសេរជំនួសខ្ញុំបាទ/នាងខ្ញុំ ។
ហេតុនេះខ្ញុំបាទ/នាងខ្ញុំសូមទទួលខុស
ត្រូវចំពោះការសរសេរនេះទាំងស្រុង ។

ស្នាមមេដៃស្តាំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
ក្រសួងសុខាភិបាល
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន
និង យុវនីតិសម្បទា
លេខ ១២៥...

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតគណៈកម្មការវាយតម្លៃកំរិតថ្នាក់បាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពនាំទៅពីរេតនៃកងយោធពលខេមរភូមិន្ទ

---

រដ្ឋមន្ត្រីក្រសួងការពារជាតិ
រដ្ឋមន្ត្រីក្រសួងសុខាភិបាល
រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន
និង យុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០៦ ស្តីពីវិសោធនកម្មច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពី ការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ។

## សម្រេច

ប្រការ១.- បង្កើតគណៈកម្មការថ្នាក់អន្តរក្រសួងមួយដែលមាន៖

-នាយក នាយកដ្ឋានសុខាភិបាល នៃអគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ ក្រសួងការពារជាតិ ជាប្រធាន

-តំណាងនាយកដ្ឋានសេវាមន្ទីរពេទ្យ នៃអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល ក្រសួងសុខាភិបាល ជាអនុប្រធាន

-តំណាងនាយកដ្ឋានសោធននិវត្តន៍ នៃអគ្គនាយកដ្ឋានយោធសេវា ក្រសួងការពារជាតិ ជាអនុប្រធានអចិន្ត្រៃយ៍

-តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ជាសមាជិក

-វេជ្ជបណ្ឌិតយោធា ផ្នែកវះកាត់ ជាសមាជិក

-វេជ្ជបណ្ឌិតយោធា ផ្នែកជម្ងឺទូទៅ ជាសមាជិក

-តំណាងនាយទាហានសុខាភិបាល ទទួលបន្ទុកគ្រប់គ្រងបំពេញសំណុំបែបបទរបស់គណៈកម្មការអន្តរក្រសួង ជាសមាជិក

ប្រការ២.- បង្កើតគណៈកម្មការកំណត់កំរិតថ្នាក់បាត់បង់សមត្ថភាពការងារថ្នាក់ក្រសួង ថ្នាក់តំបន់ប្រតិបត្តិការសឹករង ខេត្ត ក្រុង រួមមាន ÷

ក-សមាសភាពគណៈកម្មការថ្នាក់ក្រសួងការពារជាតិ :

-នាយក មន្ទីរពេទ្យព្រះកេតុមាលា ជាប្រធាន

-តំណាងនាយកដ្ឋានសេវាមន្ទីរពេទ្យ ក្រសួងសុខាភិបាល ជាអនុប្រធាន

-តំណាងនាយកដ្ឋានសោធននិវត្តន៍ នៃអគ្គនាយកដ្ឋានយោធសេវា ក្រសួងការពារជាតិ ជាអនុប្រធានអចិន្ត្រៃយ៍

-តំណាងនាយកដ្ឋានសោធនអតីតយុទ្ធជន នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ជាសមាជិក

-វេជ្ជបណ្ឌិតយោធា ផ្នែកវះកាត់ ០១រូប ជាសមាជិក

-វេជ្ជបណ្ឌិតយោធា ផ្នែកជម្ងឺទូទៅ ០១រូប ជាសមាជិក

-តំណាងនាយទាហានសុខាភិបាល ទទួលបន្ទុកគ្រប់គ្រង និងបំពេញសំណុំបែបបទរបស់គណៈកម្មការ ០១រូប ជាសមាជិក

ខ-សមាសភាពគណៈកម្មការតំបន់ប្រតិបត្តិការសឹករង ខេត្ត ក្រុង ៖

-នាយកិលានដ្ឋានតំបន់ប្រតិបត្តិការសឹករង ខេត្ត ក្រុង ជាប្រធាន

-តំណាងមន្ទីរពេទ្យ ខេត្ត ក្រុង ជាអនុប្រធាន

-ថ្នាក់សោធនទិវត្តទី តំបន់ប្រតិបត្តិការសឹករង ខេត្ត.ក្រុង ជាអនុប្រធានអចិន្ត្រៃយ៍

-តំណាងមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ជាសមាជិក

-វេជ្ជបណ្ឌិតយោធា ថ្នាក់វះកាត់ ០១រូប ជាសមាជិក

-វេជ្ជបណ្ឌិតយោធា ថ្នាក់ជំងឺទូទៅ ០១រូប ជាសមាជិក

-នាយទាហានសុខាភិបាលទទួលបន្ទុកគ្រប់គ្រង និងបំពេញសំណុំបែបបទ របស់គណៈកម្មការ

០១រូប ជាសមាជិក

* ក្នុងករណីគិលានដ្ឋានតំបន់ប្រតិបត្តិការសឹករងខេត្ត ក្រុង គ្មានវេជ្ជបណ្ឌិត គណៈកម្មការអាចជ្រើសរើសវេជ្ជបណ្ឌិតនៃមន្ទីរពេទ្យខេត្ត ក្រុង បញ្ចូលសមាសភាពគណៈកម្មការ ។

ប្រការ៣.. លក្ខណៈវិនិច្ឆ័យសំរាប់ធ្វើចំណាត់ថ្នាក់កំរិតថ្នាក់បាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ គឺការកំណត់ភាគរយដែលត្រូវបានយកតាមឯកសារចងក្រងរបស់ក្រសួងសុខាភិបាល ដែលមានឧបសម្ព័ន្ធភ្ជាប់មកជាមួយ ។

ប្រការ៤.. យោធិនបាត់បង់សមត្ថភាពការងារ ក្រោយពេលព្យាបាលជាសះស្បើយ និងមុនចេញពីមន្ទីរពេទ្យនានា គឺត្រូវបានគណៈកម្មការធ្វើការកំណត់កំរិតថ្នាក់បាត់បង់សមត្ថភាពការងារអោយបានច្បាស់លាស់ ទើបអនុញ្ញាតអោយចេញពីមន្ទីរពេទ្យ ។

ប្រការ៥.. ភារកិច្ច និង សិទ្ធិសម្រេច

ក-ភារកិច្ច :

-គណៈកម្មការគ្រប់បណ្តាថ្នាក់ មានភារកិច្ចពិនិត្យ វាយតម្លៃកំរិតថ្នាក់បាត់បង់សមត្ថភាពការងារ ចំពោះយោធិនស្ថិតក្រោមក្របខណ្ឌទទួលខុសត្រូវរបស់ខ្លួនអោយបានត្រឹមត្រូវ តាមលក្ខណៈដូចមានចែងក្នុងឧបសម្ព័ន្ធដែលក្រសួងសុខាភិបាលបានកំណត់ ។

-គណៈកម្មការគ្រប់បណ្តាថ្នាក់ ត្រូវធ្វើរបាយការណ៍តាមលំដាប់ថ្នាក់ អំពីសកម្មភាពការងាររបស់ខ្លួនរៀងរាល់ត្រីមាស និង ឆ្នាំមកគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការបូកសរុប ។

ខ-សិទ្ធិអំណាច :

-គណៈកម្មការថ្នាក់អន្តរក្រសួង មានសិទ្ធិណែនាំការងារជំនាញដល់គណៈកម្មការគ្រប់ជាន់ថ្នាក់ ។

-គណៈកម្មការថ្នាក់អន្តរក្រសួង មានសិទ្ធិពិនិត្យ វាយតម្លៃសារជាថ្មីឡើងវិញ លើការសម្រេចរបស់គណៈកម្មការថ្នាក់ក្រោមក្នុងករណីចាំបាច់ ឬមានការប្តឹងតវ៉ាពីសាមីយោធិន ។

-ក្នុងរយៈពេលរង់ចាំការវាយតម្លៃសារជាថ្មីឡើងវិញ យោធិនទាំងឡាយត្រូវអនុវត្តជាបណ្តោះអាសន្ន តាមការកំណត់របស់គណៈកម្មការដែលបានវាយតម្លៃរួចមកហើយនោះ ។

**ប្រការ៦..** អំពីរបៀបរបបការងាររបស់គណៈកម្មការគ្រប់លំដាប់ថ្នាក់ ៖

**ក-របៀបរបបការងាររបស់គណៈកម្មការ ៖**

១-ពេលវាយតម្លៃកំរិតថ្នាក់បាត់បង់សមត្ថភាពការងារ ត្រូវមានសមាជិកចំនួន ពីរភាគបីឡើងទៅ ទើបការសម្រេចវាយតម្លៃ មានលក្ខណៈត្រឹមត្រូវ ។

២-ត្រូវកំណត់ពេលវេលា និងទីកន្លែងអោយបានច្បាស់លាស់ ជូនសាមីយោធិនបាត់បង់សមត្ថភាព ការងារសំរាប់ប្រជុំវាយតម្លៃ ។

៣-យ៉ាងយឺតបំផុត ១០ថ្ងៃ ក្រោយពេលទទួលបានសំណុំលិខិត សាមីយោធិនបាត់បង់សមត្ថភាពការងារ គណៈកម្មការតាមលំដាប់ថ្នាក់ ត្រូវធ្វើការប្រជុំវាយតម្លៃតាមមុខសញ្ញា ។

៤-យ៉ាងយឺតបំផុត ១០ថ្ងៃ ក្រោយពីការវាយតម្លៃ ត្រូវចេញវិញ្ញាបនប័ត្រទទួលស្គាល់កំរិតថ្នាក់បាត់បង់សមត្ថភាពការងារ ជូនទៅសាមីយោធិនវិញ ។

៥-ក្នុងរយៈពេល ១ឆ្នាំម្តង គណៈកម្មការអន្តរក្រសួង ត្រូវធ្វើសិក្ខាសាលាបូកសរុបលទ្ធផលការងារ និងដកបទពិសោធន៍ ។

**ខ-សំណុំបែបបទដែលសាមីយោធិនត្រូវបំពេញ ៖**

ដើម្បីសម្រួលដល់ការងាររបស់គណៈកម្មការគ្រប់ថ្នាក់ សាមីយោធិនបាត់បង់សមត្ថភាពការងារ ត្រូវបំពេញរាល់សំណុំលិខិតដូចខាងក្រោម ៖

១-ពាក្យសុំធ្វើការវាយតម្លៃកំរិតថ្នាក់បាត់បង់សមត្ថភាពការងារ ដោយមានការបញ្ជាក់ទទួលស្គាល់ពីអង្គភាពដែលកំពុងគ្រប់គ្រងបច្ចុប្បន្ន ដោយភ្ជាប់រូបថត ៤ × ៦ ចំនួន ០៥សន្លឹក ។

២-លិខិតចេញពីមន្ទីរពេទ្យ បញ្ជាក់ពីលទ្ធផលព្យាបាល និងស្ថានភាពរបួសរបស់ ឬជំងឺ ដែលចេញ ដោយមន្ទីរពេទ្យចុងក្រោយបំផុត ។

៣-លិខិតទទួលស្គាល់មុខរបួស និងជំងឺរបស់សាមីយោធិនបាត់បង់សមត្ថភាពការងារ ពីបញ្ជាការ អង្គភាព ។

**ប្រការ៧..** ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារខាងលើ ត្រូវចាត់ទុកជានិរាករណ៍ ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ៨.- មេបញ្ជាការ ប្រធានស្ថាប័ន គ្រប់អង្គភាពចំណុះក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋាន និង គ្រប់ស្ថាប័នចំណុះក្រសួងសុខាភិបាល និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែ[illegible] ឆ្នាំ២០០៦

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

វេជ្ជ. នុត_សុខុម

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

អ៊ិត សំហេង

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍ ទៀ_បាញ់

<u>ចម្លងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- ក្រសួងការពារជាតិ
- ក្រសួងសុខាភិបាល
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- ឯកសារ-កាលប្បវត្តិ

# ការកំណត់ប្រភេទកំរិតថ្នាក់បាត់បង់សមត្ថភាពការងារចំពោះ
# យោធិននៃកងយោធពលខេមរភូមិន្ទ

## I/ ការកំណត់ទូទៅកំរិតបាត់បង់សមត្ថភាពបំពេញការងារត្រូវបានរៀបចំចែកជាបួនកំរិត :

### ក / . កំរិតថ្នាក់ ១

ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់យោធិនទាំងពីរភេទ ដែលមាន កំរិតបាត់បង់សមត្ថភាពបំពេញការងារលើសពី 80 % នាំឱ្យខូចខាតទាំងស្រុងនៃមុខងារសំខាន់ៗ និងជាសារវន្តមួយចំនួន ឬច្រើនរបស់សរីរាង្គកាយ ។ ជនបាត់បង់សមត្ថភាព ពុំអាចធ្វើការបំរើខ្លួនឯងបាននិងជំរុញអោយត្រូវការអ្នកដទៃជួយជាអចិន្ត្រៃយ៍ ។

### ខ / . កំរិតថ្នាក់ ២

ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់យោធិនទាំងពីរភេទ ដែលមាន កំរិតបាត់បង់សមត្ថភាពបំពេញការងារលើសពី 60 % នាំឱ្យមានការខូចខាតធ្ងន់ ឬ ស្រាលនៃមុខងារសំខាន់ៗរបស់សរីរាង្គកាយ។ ជនបាត់បង់សមត្ថភាពអាចប្រកបការងារបាននៅក្នុងករណីពិសេសសាមីជនអាចធានាបានដោយខ្លួនឯងនូវសេចក្តីត្រូវការ របស់ខ្លួនមួយផ្នែកក្នុងជីវភាពប្រចាំថ្ងៃដោយមិនចាំបាច់ពឹងផ្អែកជំនួយអចិន្ត្រៃយ៍ ពីអ្នកដទៃឡើយ ។

### គ / . កំរិតថ្នាក់ ៣

ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់យោធិនទាំងពីរភេទ ដែលមាន កំរិតបាត់បង់សមត្ថភាពបំពេញការងារលើសពី 40 % ជនបាត់បង់សមត្ថភាពអាចបំពេញការងារបាននៅក្នុងករណីដែលបានកំណត់ ហើយមិនចាំបាច់មានអ្នកដទៃជួយនៅក្នុងជីវភាពប្រចាំថ្ងៃឡើយ ។

### ឃ / . កំរិតថ្នាក់ ៤

ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់យោធិនទាំងពីរភេទ ដែលមាន កំរិតបាត់បង់សមត្ថភាពបំពេញការងារលើសពី 20 % ក្នុងករណីដែលមុខរបួសខ្សោយនៃសភាពការណ៍សុខភាពតម្រូវឱ្យប្តូរវិជ្ជាជីវៈ ឬ តម្រូវឱ្យផ្លាស់ប្តូរលក្ខណៈការងារ ។

## II តារាងកំរិតបាត់បង់សមត្ថភាពការងារគិតជាភាគរយ ( % )

| ប្រភេទជម្ងឺ របួស | ភាគរយ (%) ពិការសមត្ថភាពការងារ |
|---|---|
| **១.កំរិតបាត់បង់សមត្ថភាពបំពេញការងារផ្នែកទី១** | |
| **១.ក/ ក្បាល.មុខ .ក** | |
| 1-សំណល់នៃការប៉ះទង្គិចលលាដ៍ក្បាល : | |
| -ខ្វិនមួយចំហៀងខ្លួនមិនពេញលេញ វិបត្តិនៃការនិយាយ | 70-80 |
| -ខ្វិនមួយចំហៀងខ្លួនមិនពេញលេញ វិបត្តិសាច់ដុំលើង | 70-80 |
| -ឆ្កួតជ្រូកញឹកញាប់កើតមានច្រើនដងក្នុងមួយសប្តាហ៍ | 75-100 |
| -វិលមុខឈឺក្បាល ខួរក្បាលស្រពន់ កើតឡើងជាយូរថ្ងៃ | 40-80 |
| -ខូចខាតប្រាជ្ញាស្មារតី ភាពវិកលចរិត ភាពលំបាកធ្ងន់ធ្ងរ | 61-100 |
| 2-អន្តរាយភ្នែកទាំងពីរ កំរិតកំហើញ 1/20 | 80 |
| 3-អន្តរាយទាំងស្រុងនៃភ្នែកទាំងពីរ ( មើលអ្វីក៏មិនឃើញ ) | 90 |
| 4-បាត់បង់ឆ្អឹងថ្គាមខាងក្រោម | 60-70 |
| 5-ដំបៅបំពង់សំលេង ស្អក ដាច់បង្អាក់មិនធូរស្រាល | 50-60 |
| **១.ខ/ទ្រូង និង សរីរាង្គក្នុងទ្រូង :** | |
| 1-កាត់សួត សមត្ថភាពដកដង្ហើមចុះជាង ៥០ភាគរយ សុខភាពទូទៅត្រូវរងគ្រោះ | 55-70 |
| 2-រលាកស្រោមបេះដូង សាច់បេះដូង ស្រើសបេះដូង | 55-70 |
| **១.គ/ឆ្អឹងខ្នង :** | |
| 1-របួសឆ្អឹងជាមួយនឹងការរងរបួសបណ្តាលទៅលើខួរឆ្អឹងខ្នង : | |
| -ខ្វិនទាំងសងខាងមិនពេញលេញនៃអវយវៈក្រោម លំបាកក្នុងការធ្វើចលនា និងវិបត្តិសាច់ដុំលើង.... | 40-70 |
| 2-ខ្វិនទាំងសងខាងទាំងស្រុង នៃអវយវៈក្រោម | 70-80 |
| 3-ខ្វិនទាំងបួន ដៃពីរ ជើងពីរមិនពេញលេញ | 80-90 |
| 4-ខ្វិនបួនទាំងស្រុង ងាប់ជើងពីរដៃពីរ | 100 |
| 5-អាការៈរោគក្នុងពោះ ( គីហ្សាំង )ខ្វិនជើងទាំងសងខាង វិបត្តិ | 100 |
| **១.ឃ/ពោះនិងសរីរាង្គក្នុងពោះ** | |
| 1-របួសពោះវៀនចំទ្វារលាមកសិប្បនិម្មិត | 40-70 |
| **១.ង/ត្រគាក សរីរាង្គនៃត្រគាក ប្រដាប់បន្តពូជ :** | |
| 1-បាក់ឆ្អឹងត្រគាកជាមួយការខូចទ្រង់ទ្រាយរបស់ស្ត្រីក្នុងអាយុកាលអាចមានកូនបាន | 30-40 |
| 2-វះកាត់ស្បូន ស្ត្រីមិនដែលមានកូន | 35-45 |
| 3-វះកាត់សុដន់ទាំងពីររបស់ស្ត្រីវ័យក្មេង | 35-45 |
| 4-វះកាត់លិង្គបុរសមិនទាន់មានកូន | 25-50 |
| 5-បាត់បង់ពងស្វាសទាំងពីរចំពោះបុរសមិនទាន់មានកូន | 25-50 |
| 6-រន្ធធ្លាយ ហ្វីសស្ទុល នៃប្លោកនោម | 22-40 |

១.ឆ./អវយវៈ

1-វះកាត់ដៃទាំងពីរ មិនអំពាពកាត់ត្រង់ណា ............ 75-85

2-វះកាត់ប្រអប់ជើងទាំងពីរ............ 50-60

## ២.ពិការបាត់បង់សមត្ថភាពពលកម្មការងារថ្នាក់២

២.ក./ក្បាល មុខ ក

1-ខ្វិនមួយចំហៀងខ្លួនមិនពេញលេញ លំបាកក្នុងការធ្វើដំណើរ............ 40-70

2-ថ្គាម និង ក............ 40-60

3-ឆ្កួតជ្រូកច្រំដែល............ 30-45

4-វិលមុខ ឆ្កួតជ្រូក ស្រាលពីរដងក្នុងមួយសប្តាហ៍............ 30-40

5-ឆ្កួតជ្រូក ឃ្លាតអង្គែ កើតវិបត្តិជាប់ៗគ្នា............ 30-50

6-និយាយមិនចេញ............ 30-50

7-វិបត្តិពីក្រោយពីការប៉ះទង្គិច ( អាការៈមាត់និង សារ៉ុន ៧១០ មេរី រ៉ូម៉េ )............ 30-40

8-ភាពល្ងិតល្ងង់ក្រោយពីការប៉ះទង្គិច............ 30-40

9-ឈឺរោយមុំស្មុគៈ ភាពរំភើបខ្លាំង............ 30-40

10-ផ្លាកនោមស្វ័យប្រវត្តិ អាការៈមាត ពីញ៉ាល............ 20-40

11-សតិ ប្រាជ្ញាតន់ខ្សោយ ............ 45-60

12-មានសតិ ស្រុតចុះ............ 40

13-ថ្លង់សងខាងទាំងស្រុង............ 45

14-មិនចាំបំពង់សំលេង វះបោះបំពង់ខ្យល់............ 50-60

15-បំពង់អាហារមួយចំ តម្រូវឲ្យចោះក្រពះ............ 40-60

16-កំហើញនៃភ្នែកទាំងពីរធ្លាក់ចុះ _ កំរិតកំហើញ 2/10............60

_ កំរិតកំហើញ 1/10............70

17-បាត់បង់ឆ្អឹងថ្គាមខាងលើ............ 50-60

18-ភ្លាត់ឆ្អឹងថ្គាម ( អាចយកចេញនៃសារជាតិ ) ............ 40-60

19-ខ្វិនសាច់ដុំអណ្តាតទាំងស្រុង............ 50

20-អណ្តាតត្រូវកាត់ផ្តាច់ដោយសារការប៉ះទង្គិច............ 50

២.ខ./ទ្រូង និង សរីរាង្គទ្រូង

1-កាត់បន្ថយសមត្ថភាពដកដង្ហើមថយចុះលើសពី 50 % ត្រូវការជាប្រចាំ............35-45

2-ចំណាល់ផលិតស្រាមបេះដូង សាច់បេះដូង ស្រោមបេះដូងមិនបណ្តាលអោយមានវិបត្តិដល់

មុខងារសំខាន់ៗរបស់បេះដូង............30-50

២.គ./ឆ្អឹងខ្នង :

1-ខ្វិនជើងសងខាងមិនពេញលេញ មានសមត្ថភាពផ្លាស់ទីកន្លែងបាន............25-40

2-ខូចខ្ទាស់ឆ្អឹងខ្នងទាំងសងខាង............ 25-40

3-បាក់ឆ្អឹងកងខ្នង ( សាកត្រម ) និងវិបត្តិសាច់ដុំលិង............25-35

២.ឃ./ពោះនិងសរីរាង្គក្នុងពោះ

1-ការបះខ្ញិចផ្ទៃពោះមិនបានល្អដែលត្រូវធ្វើជាមួយនឹងការបំពាក់ក្រវាត់ឲ្យណែនល្មមល្អ ...... 35-55

2-វះកាត់ក្រពះ ...... 40-60

3-វះកាត់ពោះវៀនធំហើយសល់តែមួយម៉ែត្រជាមួយវិបត្តិនៃការរំលាយអាហារ ...... 35-60

4-របួសពោះវៀនធំនិងផ្លាយវៀន ( ហ្វិស្ទុល ) នៅភាគខាងឆ្វេង ...... 25-40

5-រន្ធផ្លាយនៃពោះវៀនធំនិងការហូរលាមក ...... 30-40

6-ទោះធ្លាក់នោមនៃផ្លែពោះ ( រន្ធនោមសិប្បនិម្មិត ) ...... 30-40

7-កាត់តំរងនោមម្ខាង : _អ៊ុយរ៉េឈាម 0,6-1g2/L ...... 35-45

_អ៊ុយរ៉េឈាម 1g2/L ...... 45-65

8-ផ្លាយខ្ទុះនៃថ្លើមហើយកាត់ប្រមាត់ ...... 25-40

២.ង./ត្រគាក សរីរាង្គនៃត្រគាក ប្រដាប់ភេទ :

1-បាក់ឆ្អឹងត្រគាកជាមួយការខូចទ្រង់ទ្រាយរបស់ស្ត្រីក្នុងអាយុកាលអាចមានកំណើតកូនបាន ...... 30-40

2-វះកាត់ស្បូន ស្ត្រីមិនដែលមានកូន ...... 35-45

3-វះកាត់សុដន់មាតាលើស្ត្រីវ័យក្មេង ...... 35-45

4-វះកាត់លិង្គបុរសមិនទាន់មានកូន ...... 35-45

5-បាត់បង់ពងស្វាសទាំងពីរចំពោះបុរសមិនទាន់មានកូន ...... 25-50

២.ច./អវយវៈ

1-បាត់បង់ប្រអប់ដៃម្ខាង ...... 35-40

2-វះកាត់ត្រង់សន្លាក់ឆ្អឹងកដៃ ...... 35-40

3-វះកាត់កំភួនដៃ ...... 40-45

4-វះកាត់ត្រង់សន្លាក់ឆ្អឹងកែងដៃ ...... 40-45

5-វះកាត់ដើមដៃ ផ្នែកកណ្តាលខាងក្រោម ...... 45-50

ផ្នែកកណ្តាលខាងលើ ...... 50-55

6-វះកាត់ត្រង់សន្លាក់ឆ្អឹងស្មារ ...... 55-60

7-ខ្វិនទាំងស្រុងដៃម្ខាង ...... 45-50

8-អាការៈបាត់នៃការចលនាទាំងអស់ ក្លូសាល់ហ្សី ខូចខាតទាំងស្រុងនីមួយដៃម្ខាង ...... 45-50

9-វះកាត់កំភួនជើងម្ខាង ...... 35-40

10-វះកាត់ត្រង់សន្លាក់ជង្គង់ ...... 35-40

11-វះកាត់ភ្លៅ ...... 45

12-ខ្វិនទាំងស្រុងនៃជើងម្ខាង ...... 45

13-ភ្ជាប់សន្លាក់ចង្កេះជាមួយរូបសាច់ដុំភ្លៅ ...... 45

14-វះកាត់ត្រង់សន្លាក់ឆ្អឹងចង្កេះ ផ្លាស់សន្លាក់ឆ្អឹងចង្កេះ ...... 50-70

២.ឆ./ជម្ងឺផ្សេងៗ

1-របេងខួរក្បាលដាហ្វ៊ីប៊្រី បណ្តាលមកពីការប៉ះទង្គិច រឺមកពីជម្ងឺវិជ្ជាជីវៈ ...... 30-50

៣.កំរិតបាត់បង់សមត្ថភាពពីការងារថ្នាក់៣

៣.គ/មុខ ក្បាល.ក

1-រលាត់ស្បែកលលាដ៍ ....

2-កាត់ឆ្អឹងលលាដ៍ចោលមួយចំណែក: _ វិទ្យមាត្រលើសពី : 6 cm .... 20-30

_ វិទ្យមាត្រលើសពី : 10 cm .... 30-40

3-អង្គធាតុចម្លែកនៅក្នុងប្រអប់លលាដ៍ .... 20-40

4-ហេមីប្លេហ្ស៊ី .... 20-40

5-និយាយមិនលឺស្មើរទាំងស្រុង .... 20-30

6-ឆ្កួតជ្រូកទូទៅ _ វិបត្តិធ្ងន់ ១.២ ដងក្នុងមួយខែ .... 15-35

_ វិបត្តិស្រាល ៣.៤ ដងក្នុងមួយខែ .... 10-25

7-វិលមុខឬចុកខ្លាំង ( ឆ្កួតជ្រូកស្រាល ) សណ្ឋានស្រាល .... 20-30

8-ឆ្កួតជ្រូកជិតខ្លួន ( មិនមែនឆ្កួតជ្រូក ) ហ្សាកសុន មួយដងក្នុងមួយសប្តាហ៍ .... 20-30

9-ចលនាមិនធម្មតា ( ញ័រ ទាញរឹត ប្រកាច់សំពាធក្នុងការងារអនុវត្តន៍ទិសដៅជាក់លាក់ ) .... 10-40

10-អាការៈរោគផ្តាល់ខ្លួន ( ស៊ីហ្វូរ៉ូកាឌី ) បន្ទាប់ពីមានការរងរបួសខ្លួន (ក្លូស្យូងសម្រាល ) .... 20-30

11-អស់សតិបន្ទាប់ពីការប៉ះទង្គិច ( សណ្ឋានមធ្យម ) .... 20-30

12-អ៊ីប៉ែរហ្ស៊ីមីណេ ភាពរំភើបចិត្តខ្លាំងជារៀងរហូត មិនសូវសណ្ឋានមធ្យម .... 20-30

13-សភាពស្រុតចុះនៃឈាម ( មធ្យម ) .... 10-30

14-សណ្ឋានឆ្កួតជ្រូកនាពេលក្រោយ .... 25-30

15-ថ្លង់ទាំងសងខាងមិនពេញលេញ .... 30-40

16-ប៉ះប៉ង់មុខរូបខ្លួន ( ឯកវៀចខាងមាត់ ) .... 20-30

17-អន្ធការភ្នែកម្ខាងខួរខ្សោយប្រាប់ភ្នែកម្ខាងទៀត .... 25-30

18-ខ្វាក់ភ្នែកម្ខាង មានលទ្ធភាពដាក់កែវភ្នែក .... 25-70

_ គ្មានលទ្ធភាពដាក់កែវភ្នែក .... 30-35

19-បាក់ឆ្អឹងថ្គាមខាងលើ ( កន្លែងបាក់មិនជាប់ ) រួមផ្សំនិងភ្ជាស់សន្លាក់ធ្មេញថ្គាមមិនអាចទំពារបាន... 30-35

20-បាក់ឆ្អឹងថ្គាមខាងក្រោម ( កន្លែងបាក់មិនជាប់ )ធ្វើអោយធ្មេញលើនិងក្រោមត្រូវសង្កត់ .... 20-30

21-សន្លាក់ថ្គាមជាប់រឹងមិនអាចហាបើកឆ្អឹងថ្គាមទាំងពីរឱ្យហួសពី ១០សម .... 15-40

22-បាត់បង់អណ្តាតមួយភាគ និយាយមិនបានច្បាស់ .... 20-30

23-ថ្លង់ឥតបញ្ញាលមកពីអនុភាពសម្ពាធខ្យល់នៃការផ្ទុះ _សណ្ឋានធ្ងន់ធ្ងរ .... 40-60

_សណ្ឋានមធ្យម .... 20-40

៣.ខ/ទ្រូង និង សរីរាង្គក្នុងទ្រូង :

1-បាក់ឆ្អឹងជំនីខ្វះទ្រទ្រង់ខ្សោយប្រអប់ទ្រូងជាមួយសំណល់បាតរបួសភ្ជុះស្ដាយក្រោមសួត .... 25-35

2-ផលវិបាកនិងសំណល់រោគវិទ្យារបួសស្រោមសួត ( ឈាមក្នុងស្រោមសួត ខ្យល់ក្នុងស្រោមសួត ស្រោមសួតស្អិតជាប់ថ្លោះស៊ីបង្អាក់ ) .... 20-30

3-ស្រោមសួតសមត្ថភាពថយចុះជាង 50 % .... 25-35

4-អំបែងគ្រាប់កាំភ្លើងនៅក្នុងសួតបណ្តាលអោយមានលទ្ធភាពបើក្នុងទ្រូងចង្អៀតចង្អល់ .... 25-30

5-ការរួមតូចនៃបំពង់អាហារបណ្តាលពីការប៉ះទង្គិចទីការលេបរបស់ដែលបង្កគ្រោះថ្នាក់នៅសារធាតុគីមីស្ទើរ...... 20-40

៣.គ./ឆ្អឹងខ្នង ៖

1-រឹងឆ្អឹងខ្នងពេលងាកទៅមុខនិងបញ្ឆិត ត្រូវចុះនិងឡើងជាប់........................

2-អាការៈរោគ (កន្ទុយសេះ) ទល់នោមមិនចេញសោះ........................

៣.ឃ./ពោះនិងសរីរាង្គក្នុងពោះ

1-វះកាត់ក្រពះ គ្មានផលវិបាក........................20-25

_មានផលវិបាកជាប់រ៉ាំរ៉ៃវិបត្តិការរំលាយអាហារសុខភាពខ្សោយទៅជាយូរ........................25-35

2-វះកាត់ពោះវៀនតូចលើសពីមួយម៉ែត្រគ្មានផលវិបាកនិងគ្មានវិបត្តិការរំលាយអាហារ........................25-30

3-រន្ធផ្លាយ ( ហ្វីស្ទុល ) ពោះវៀន

_រន្ធផ្លាយនាំទៅភាគខាងលើ........................25-40

_រន្ធផ្លាយនាំទៅភាគខាងក្រោម........................20-30

4-រន្ធផ្លាយខួរបណ្តាលអោយជាប្រចាំចេញតាមស្បែកពីទឹកលាមក........................20-30

5-ការប៉ះពាល់ផល (ស្ពិនទែ) លាមកបណ្តាលអោយបញ្ចេញលាមកទប់មិនបាន........................20-35

6-កាត់ថ្លើមជាមួយវិបត្តិនៃមុខងារថ្លើម........................10-30

7-វះកាត់ដំរងនោមម្ខាងទៀតធម្មតា........................25

៣.ង./ត្រគាក សរីរាង្គនៃត្រគាក ប្រដាប់បន្តពូជ ៖

1-រន្ធផ្លាយ ហ្វីស្ទុល នៃប៉េរីណេ........................20-40

2-ការរួមតូចនៃទ្វារនោម ( អ៊ុរិត )

_ត្រូវព្យាបាលដោយពង្រីកជារៀងរាល់ខែ........................20-30

_ជាមួយរន្ធផ្លាយ ហ្វីស្ទុល........................25-40

3-វះកាត់បង្គួរលើបុរសដែលមានកូនហើយ........................25-35

4-វះកាត់ស្បូនស្ត្រីអាយុតិចជាង ៤៥ ឆ្នាំដែលមានកូនរួចហើយ........................25-35

5-វះកាត់សុដន់ទាំងពីរលើស្ត្រីដែលមានកូនរួចហើយ........................20-40

6-រន្ធផ្លាយពីប្លោកនោមទៅទ្វារមាស........................20-30

៣.ច./អវយវៈ

1-ដាច់បង់ដៃមួយ និងចង្អុលដៃមួយ........................25-30

2-ដាច់បង់ម្រាមដៃមេ ពីទំពាំងក្រោយណា........................25-30

3-ដាច់បង់ម្រាមដៃទាំងប្រាំ........................30-35

4-ម្រាមដៃមាំងត្រើបត្រឡប់........................25-30

5-សន្លាក់កែងបញ្ឈរនៃឆ្អឹងកំភួនដៃទាំងពីរ........................20-30

6-កាំងសន្លាក់កែងដៃស្ថិតនៅក្នុងមុំ ១១០ ទៅ ១៨០ អង្សា........................25-30

7-បាក់ឆ្អឹងដើមដៃជាមួយសន្លាក់ក្លែងក្លាយ........................25-35

8-បាក់ឆ្អឹងដើមដៃតភ្ជាប់មិនជាប់ ចលនារបស់សន្លាក់ស្មាថយចុះ........................25-30

9-កាំងសន្លាក់ស្មា ៖ ចលនាកន្ត្រាក់ចេញពី ៤៥ អង្សា........................25-30

ចលនាកន្ត្រាក់ចេញពី ១០អង្សា........................30-35

10-ខូចណែរ៉្វ ម៉េឌីយ៉ង់........................25-30

11-ខូចសរសៃ វាយក្បាលនៅភាគខាងលើ នៃច្រើមប្រអប់ជើងធ្លាក់ចុះ........................................ 25-30

12-ខូចសរសៃខាងលើ ភាពតឹងទ្បើង សញ្ញាននុយរ៉ែនវេរិស........................................ 25-30

13-ខូចសរសៃខាងក្រោមសញ្ញាតួមប៉ូ ខូចសាច់ដុំម្ហូស៊ីសំព្រោងជើង........................................ 25-35

14-អាការៈលោតរៀលប្រសព្វព្យែមរឺស៊ីសំព្រោមម៉ោងដាយ អ៊ីប៉ូរ៉ាលូយឡារ៉ីសាស្ដ្រមហាប្រព្ធមគវីបិះខ្ទប៉ិទ........ [illegible]

15-កាត់បង់ម្រាមជើងទាំងប្រាំ និងឆ្អឹងបាតជើង........................................ 20-25

16-កាត់បង់ប្រអប់ជើងសល់នៃកាត់កាណាអូម ឆ្អឹងកែងជើង ឬ កាត់សន្លាក់តាមរបៀប ( ចូពា )........ 25-30

17-ការកាត់តាមរបៀបហ្ស៊ីហ្វង់ វីកាដង់ ពីរ៉ូហ្គូហ្វ........................................ 25-30

18-រះកាត់សន្លាក់កជើង........................................ 35

19-ដាក់ផ្ដាច់ទីប៉ូស៊ីណាំងសន្លាក់ជង្គង់........................................ 20-30

20-ដាក់ឆ្អឹងស្នងទាំងពីរឆ្អឹងតមិនជាប់ ស្នងបៀចហើយរួញខ្លីជាង ៥ សម ........................ 20-25

21-សន្លាក់ក្លែងក្លាយនៃស្នង ........................................ 25-35

22-ដាក់ ឬ កាត់យកឆ្អឹងអង្គុយចេញពាំងសន្លាក់ជង្គង់ ឬ ស៊ិតគ័រគ្រីស៊ិច........................ 15-25

23-សំណល់ខ្សែរដ៏នៃការប៉ះពាល់ជង្គង់ដោយសន្លាក់ជង្គង់ស្នងបត់បានពី ១៥០ទៅ ១៣៥ អង្សា.......... 20-30

24-ដាក់មួយភាគបីកណ្ដាល ឬ ក្រោមឆ្អឹងភ្លៅឆ្អឹងតមិនជាប់ ឆ្អឹងបៀចរួញខ្លីលើសពី ៤ សម.................. 20-30

25-ដាក់មួយភាគបីខាងលើឆ្អឹងភ្លៅ ឆ្អឹងតមិនជាប់........................................ 25-30

26-តាំងសន្លាក់ចង្កេះ ឆ្អឹងភ្លៅមិនបៀច ........................................ 25-30

27-តាំងសន្លាក់ចង្កេះ ឆ្អឹងភ្លៅបៀច........................................ 30-35

28-សន្លាក់ទាញនៃការរលាកនៅសន្លាក់ជង្គង់ ឬ នៅចង្កេះ........................................ 30-35

29-ជម្ងឺរលាកឆ្អឹង និងខួរឆ្អឹងរង្គាលរីករាលដាលច្រើនកន្លែង សារធាតុ........................................ 20-50

៥.<u>ពិការភាពបាត់បង់សមត្ថភាពបំពេញការងារថ្នាក់៥</u>

៤.<u>ក/មុខ.ក្បាល.ក</u>

1-បាត់បង់មួយភាគឆ្អឹងលលាដ៍ វិផ្នមាត្រ ២សម........................................ 15-20

2-អន្តរាយភ្នែកម្ខាង ម្ខាងទៀតធម្មតា........................................ 25

3-ឆ្អឹងថ្គាមខាងលើ _បាត់បង់ច្រើនភាគច្រើនធ្មេញលម្អភាពពាក់ធ្មេញបាន........................ 20

_បាក់តមិនជាប់សមត្ថភាពនៃការទំពារថយចុះ........................................ 20-25

_ធ្មេញរបើនិងក្រោមថ្ពុសក្ដាតិចតួច........................................ 15-20

_ខ្ទះឆ្អឹងក្រអូមមាត់ធ្វើអោយមានការតភ្ជាប់រវាងមាត់និងច្រមុះ........................ 20-30

4-ឆ្អឹងថ្គាមក្រោម:

_ឆ្អឹងថ្គាមបាក់តមិនជាប់ (ចំណាត់ថ្នាក់ទៅតាមសមត្ថភាពការទំពារភ្ជាក់ឆ្អឹងថ្គាមសារជាតិ )...... 20-25

_បាត់អណ្ដាតមួយភាគ រអាក់រអួលដល់ការនិយាយស្ដី ការទំពារនិងលេបអាហារ.................. 10-20

5-ថ្ពាល់ទាំងសងខាង តិចមធ្យម........................................ 20-25

6-កាត់ច្រមុះចោល ( ត្រូវឱ្យផ្លាស់ប្ដូរមុខវិជ្ជាជីវៈ )........................................ 10-20

7-របោសស៊ីស្រមថ្គាម ថ្ពាស និង អ៊ីតូស៊ីតចំណាត់ថ្នាក់ទៅតាមភាពធ្ងន់ធ្ងរនៃជម្ងឺនិងចំនួនសឹទ្ធស៊ីលទ្ធផលប្រតិបត្តិ.... 10-30

8-វិបត្តិពាក្យសម្ដី និងវិបត្តិបញ្ចេញមួយហេតុ : _ខ្វិនគួរលំគួរ

_សម្លាកនៅបំពង់សំលេង ( បើមក )

_រលាកសន្លាក់ត្រគាក អាថ្រូសេរ៉ូស៊ីត

ពិការយមិនល្អ......................................................20-60

ខាត់បង្គត់មធ្យម......................................................15-20

9-សំណល់បំពេញចំហៀបពីសន្ទះខ្សប់នៃការផ្ទុះ

_អាការៈរោគផ្ទាល់ខ្លួនដាច់ដាចផ្លូវការរញ្ជួយខួរសណ្ឋានស្រាល......20

_វិបត្តិរាក្យសិទ្ធិនិងអារម្មណ៍ស្ពាប់ស្ងួតស្ងាត់......................10-20

_ជម្ងឺចាស្មរ៉ៈ កើតឡើងពីខែចំបូងក្រោយការបំពេញចិត្ត......................5-20

_ជម្ងឺឥតនោមផ្អែមក្រោយការប៉ះទង្គិចលលាដ៍ ឬ ពេលសុពាងាយប៉ះទង្គិច..... 25

10-របួសផ្នែកខាងក់នៅស្មារ និងស្វាយផាំសាច់ដុំ ( ក ) និងមុខ......................15-20

<u>៤.១/ទ្រូង និង សរីរាង្គក្នុងទ្រូង :</u>

1-កាត់សួត សមត្ថភាពថយចុះជាង 50 % សួតភាពខ្វះខាត់ផ្លូវដង្ហើម......................55-70

2-ប៉ះពាល់ជាល់ស្រោមបេះដូង សាច់បេះដូងក្រេប៉ីសបេះដូងបង្ហូរឈាម......................55-70

<u>៤.៨/ពោះនិងសរីរាង្គក្នុងពោះ</u>

1-របួសពោះប៉ះទំនួរបេលាកសិល្បចិន្ដិត......................40-70

2-ការប៉ះទង្គិចផ្នែកពោះប៉ះពាល់ដល់ក្រពះជាមួយអាសិដគចំពៅក្រពះខ្វះឈាមស្ទះស្លាំង......................35-55

3-វះកាត់ក្រពះ......................40-60

4-វះកាត់ពោះវៀនតូចឬលើសពីមួយម៉ែត្រជាមួយវិបត្តិនៃការរំលាយអាហារ......................35-60

5-របួសពោះវៀនធំនិងថ្លាមរន្ធ ( ហ្វីសស្ទុល ) កំណែភាគខាងលើ......................25-40

6-រន្ធថ្លាមទាំងនៃពោះវៀនធំនិងការហូរលាមក......................30-40

<u>៤.ឃ/ផ្លូវទឹកនោម សរីរាង្គនៃទឹកនោម ប្រដាប់បន្តពូជ :</u>

1-វះកាត់ពងស្វាសទាំងពីរលើបុរសអាយុលើសពី ៥០ ឆ្នាំ......................10-20

2-វះកាត់ស្បូនចំពោះស្ត្រីអាយុលើសពី ៤៥ឆ្នាំ ដែលមានកូនរួចហើយ......................20-25

3-សម្លាកប្រើតកន្លែងរបស់ទ្វារមាសនិងយោនី......................10-25

4-វះកាត់សុដន់ចោលម្ខាងនៃស្ត្រី ឬ ម្ដាយស្រី......................10-20

5-បាត់ទឹកដូង ( សាត្រូម ) ជាមួយវិបត្តិសាច់ដុំរលើង......................20-25

<u>៤.ង/អវយវៈ</u>

1-បាត់បង់មេដៃ និងឆ្អឹងបាតដៃ......................18-21

2-បាត់បង់ចង្អុល និងម្រាមដៃពីរទៀតក្រៅពីមេដៃ......................20-22

3-បាត់បង់មេដៃ និងម្រាមមួយទៀត ក្រៅពីចង្អុលដៃ......................20-22

4-បាត់បង់មេដៃ និងម្រាមពីរទៀត ក្រៅពីចង្អុលដៃ......................22-25

5-សន្លាក់នៃការលាតត្រង់ម៉ែដៃនិងម្រាមដៃ ឬ មិនអាចលាតបាន :

_ម្រាមដៃទាំងប្រាំ......................25-30

_មេដៃនិងចង្អុលដៃ......................20-25

_មេដៃនិងម្រាមបីមួយទៀត......................15-20

6-សន្លាក់ទាញទៅក្រោយដែលកំណត់ចលនាកំភួនដៃ :

_លាតសន្ធឹងពី ១៨០ ទៅ១១០ អង្សា........................................ 20-25

_កំណត់ពី១១០ ទៅ ៧៥ អង្សា........................................ 15-20

_កំណត់ពី ៧៥ ទៅ ៣៥ អង្សា........................................ 10-15

7-សន្លាក់ទាញទៅក្បៀក ដែលកំណត់ចលនាស្មា :

_លើកដៃកន្លែកចេញ ៤៥ អង្សា........................................ 20-25

_លើកដៃកន្លែកចេញ ១០ អង្សា........................................ 25-30

8-តាំងសន្លាក់កដៃជាមួយនឹងការខាតមុខងារនៃម្រាមដៃ :

_ឥរិយាបថទទួលការងារ........................................ 15-20

_ឥរិយាបថ៩ បង់ ........................................ 20-25

9-បាក់ឆ្អឹងកំភួនដៃទាំងពីរឆ្អឹងតមិនជាប់ អក់ស្រឹងប្រៀត ឆ្អឹងរួញខ្លី........................................ 15-25

10-តាំងសន្លាក់កែងដៃជាមួយបំណាក់កំភួនដៃពី ៦០ ទៅ ១១០ អង្សា........................................ 15-25

11-តាំងសន្លាក់ស្មាលើដៃកន្លែកចេញ ៩០អង្សា........................................ 10-25

12-ខ្វិនសរសៃមេដ្យង់ទៅកែងដៃ........................................ 20-25

13-ខ្វិនសរសៃ គុយប៊ីតាល់........................................ 15-25

14-ខ្វិនសរសៃ រ៉ាដ្យាល់នៅខាងក្រោមត្រីសិប........................................ 20-25

15-បាក់ឆ្អឹងដងកាំបិត ឆ្អឹងតមិនជាប់ជាមួយសញ្ញាសម្ពន្ធភាព........................................ 15-25

16-បាក់ឆ្អឹងស្លាបប្រចៀវ........................................ 10-30

17-ដាច់បង់ម្រាមជើងប្រាំ........................................ 5-10

18-ដាច់បង់ឆ្អឹង អាស្ត្រាហ្គាល់........................................ 25

19-ដាច់បង់ឆ្អឹងកែងជើង ........................................ 25-30

20-ដាច់បង់ឆ្អឹងផ្នែកខាងទាំងពីរស្មូតប៉ែ........................................ 15-20

21-តាំងសន្លាក់ជើង........................................ 15-20

22-បាក់ឆ្អឹងស្មងទាំងពីរ ទីប្យ៉ា ប៉េរ៉ូណេ ឆ្អឹងតមិនជាប់ ស្មងវៀច ឆ្អឹងរួញខ្លីបិចជាង ៥សម........................................ 15-20

23-ស្ទើរតែដាច់ជង្គង់អនុគ្រោះដល់ឥរិយាបថស្មងជើង ១៣៥ ទៅ ១៨០អង្សា........................................ 15-20

24-អង្គធាតុបរទេសនៅក្នុងសន្លាក់ជង្គង់........................................ 10-25

25-តាំងសន្លាក់ជង្គង់ឥរិយាបថរបស់ស្មងត្រង់ឆ្អឹង ១៨០ អង្សា........................................ 15-25

26-សន្លាក់ទាញការរលាកនៅសន្លាក់ជង្គង់កំណត់ចលនាបត់និងលាពី ៩០ ទៅ១៣៥អង្សា........................................ 10-30

27-រហូតស្មងជើងសន្លាក់ទាញជាមួយនៃការរួញខ្លីនៃសរសៃកែង........................................ 15-25

28-បាក់មួយភាគបីខាងលើឆ្អឹងភ្លៅ ឬ ឆ្អឹងភ្លៅតមិនជាប់........................................ 25-30

29-ខ្វិនសរសៃ ស្យាទិក........................................ 25

30-ខ្វិនសរសៃ ស្យាទិកចំណាត់ថ្នាក់តាមកំរិតនៃការឈឺចាប់ និងកំរិតនៃការពិបាកធ្វើដំណើរ........................................ 10-25

31-ភ្នាត់និងតាំងសន្លាក់ចង្កេះ........................................ 20-25

32-រលាកឆ្អឹងនិងខួរឆ្អឹងជាមួយនិងទន្លាយច្រើនកន្លែង........................................ 20-30

33-ស្វិតសាច់ដុំឈឺចាប់ចំពោះស៊ីអ៊ះយ៉ះ បណ្តាលមកពីការព្យាបាលដោយស៊េរ៉ូមអង់ទីតេតានិក........................................ 20

34-អាណាក្សែរភាទែរ បំនំរនអះយៈ ចំណាត់ថ្នាក់ទៅតាមវិបត្តិនៃការឈឺចាប់និងវិបត្តិនៃមុខងារធ្វើចលនា 5-20

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: [illegible]

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការកំណត់ប្រាក់ធ្វើដំណើរ ប្រាក់ហូបចុកពេលទៅ ពេលមក និងប្រាក់ឧបត្ថម្ភ ដើម្បីជួយសម្រួលជីវភាពរស់នៅក្នុងគ្រួសាររបស់យោធិនអាជីពទាំងពីរភេទ ដែលបានច្បាប់ឈប់សម្រាកក្នុងប្រទេសមុនពេលចូលនិវត្តន៍

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពី ការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទ នៃកងយោធពលខេមរភូមិន្ទ

ដើម្បីមានមូលដ្ឋានក្នុងការធានាប្រាក់ធ្វើដំណើរ ប្រាក់ហូបចុកតាមផ្លូវ ទាំងទៅ ទាំងមក និងប្រាក់ឧបត្ថម្ភ ដើម្បីប្រុងប្រៀបជីវភាពរស់នៅក្នុងគ្រួសារចំពោះយោធិនអាជីពទាំងពីរភេទ នៃកងយោធពលខេមរភូមិន្ទដែលស្ថិតក្នុងមុខសញ្ញាសោធននិវត្តន៍ ហើយត្រូវទទួលបានច្បាប់ឈប់សម្រាកក្នុងប្រទេសមុនពេលបង្កើតបានបៀវត្សរ៍សោធនយោធា ។

## សម្រេច

**ប្រការ១** : ចំពោះយោធិនអាជីពទាំងពីរភេទ នៃកងយោធពលខេមរភូមិន្ទ ត្រូវទទួលបានប្រាក់ធ្វើដំណើរ ប្រាក់ហូបចុកទាំងទៅ ទាំងមក និងប្រាក់ឧបត្ថម្ភ ដើម្បីប្រុងប្រៀបជីវភាពរស់នៅក្នុងគ្រួសារនៅពេលបានច្បាប់ឈប់សម្រាកក្នុងប្រទេសមុនពេលចូលនិវត្តន៍ ដូចមានចែងក្នុង ជំពូកទី២ មាត្រា១០ នៃអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៦ ។

**ប្រការ២** : យោធិនអាជីពទាំងពីរភេទ នៃកងយោធពលខេមរភូមិន្ទ ដែលបានច្បាប់ឈប់សម្រាកក្នុងប្រទេសមុនពេលចូលនិវត្តន៍ ក្នុងម្នាក់ត្រូវទទួលបានប្រាក់ឧបត្ថម្ភ ដូចតទៅ ៖

១-ប្រាក់ធ្វើដំណើរ ចំនួន ០២ថ្ងៃ : ៨.០០០៛ x ២ថ្ងៃ = ១៦.០០០៛

២-ប្រាក់ហូបចុក ចំនួន ០២ថ្ងៃ : ១៥.០០០៛ x ២ថ្ងៃ = ៣០.០០០៛

៣-ប្រាក់ឧបត្ថម្ភដើម្បីប្រុងប្រៀបជីវភាពរស់នៅក្នុងគ្រួសារ (ស្នាក់នៅ) ចំនួន ០៤ថ្ងៃ

: ៤០.០០០៛ x ៤ថ្ងៃ = ១៦០.០០០៛

**សរុប** : ១ + ២ + ៣ = ២០៦.០០០៛

**ប្រការ៣** : -ក្រសួងការពារជាតិ : ត្រូវលើកគម្រោងថវិកាជារៀងរាល់ឆ្នាំអោយបានមុនខែកក្កដា នៃឆ្នាំនីមួយៗទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីធ្វើការធានាទុកផលទានសំរាប់ឧបត្ថម្ភដល់យោធិនស្ថិតក្នុងមុខសញ្ញាសោធននិវត្តន៍ ។

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ : មានភារកិច្ចពិនិត្យសំរេចលើសុំផលទានថវិកាសំរាប់ចំណាយឧបត្ថម្ភ ប្រាក់ធ្វើដំណើរ ប្រាក់ហូបចុកទាំងទៅ ទាំងមក និងប្រាក់ឧបត្ថម្ភ ដើម្បីប្រុងប្រៀបជីវភាពរស់នៅក្នុងគ្រួសារពេលបានច្បាប់ឈប់សំរាកច្បាប់ក្នុងប្រទេស របស់យោធិនអាជីពទាំងពីរភេទស្ថិតក្នុងមុខសញ្ញាសោធននិវត្តន៍ ។

ប្រការ៨ : ប្រកាស និង លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៩ : មេបញ្ជាការ ប្រធានស្ថាប័ន គ្រប់កងឯកភាពចំណុះក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋាន និង គ្រប់ស្ថាប័ន ចំណុះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី.........ខែ.........ឆ្នាំ២០០..

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍ ទៀ-បាញ់

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
"ដើម្បីជូនជ្រាប"
-ក្រសួងការពារជាតិ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ: ០០៦/០៨ ២០០៨

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៨

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

ជម្រាបមក

**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ**

**ឯកឧត្តម ប្រធានស្ថាប័ន គ្រប់ឯកភាពចំណុះក្រសួងការពារជាតិ**

**កម្មវត្ថុ** : ស្តីពី ការបង្កើតគណៈកម្មការវាយតម្លៃកម្រិតថ្នាក់បាត់បង់សមត្ថភាពការងារ ថ្នាក់អន្តរក្រសួង ថ្នាក់ក្រសួង និង ថ្នាក់តំបន់ប្រតិបត្តិការសឹករងខេត្ត-ក្រុង ។

**យោង** : - អនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ។

- ប្រកាសអន្តរក្រសួងលេខ ១២៨ ប្រក.អន ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ របស់ក្រសួងការពារជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង ក្រសួងសុខាភិបាល ស្តីពីការបង្កើត គណៈកម្មការវាយតម្លៃកម្រិតថ្នាក់បាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ។

តាមកម្មវត្ថុ និង យោងខាងលើ ដើម្បីមានមូលដ្ឋានក្នុងការពិចារណាដោះស្រាយគោលនយោបាយដល់យោធិនដែលស្ថិតក្នុងស្ថានភាពបាត់បង់សមត្ថភាពការងារ សូមឯកឧត្តមដែលជាប្រធានស្ថាប័ន កងឯកភាព មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត - ក្រុង ត្រូវសហការរៀបចំសមាសភាពគណៈកម្មការវាយតម្លៃកម្រិតថ្នាក់បាត់បង់សមត្ថភាពការងារ តាមបណ្តាថ្នាក់នីមួយៗ រួចផ្ញើមកអគ្គនាយកដ្ឋានយោធសេវា (នាយកដ្ឋានសោធននិវត្តន៍) ឱ្យបាន មុនថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៨ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម ប្រធានស្ថាប័ន កងឯកភាពចាត់ចែងអនុវត្តន៍តាមការគួរ ។

សូមឯកឧត្តម ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

រដ្ឋមន្ត្រី

នាយឧត្តមសេនីយ៍ ទៀ-បាញ់

ទីស្តីការក្រសួងការពារជាតិ ទូរស័ព្ទ-ទូរសារ : (៨៥៥) ០២៣ ៨៨៣២៧៤ E.Mail : Minadif@camnet.com.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ: ០០៥២ / ស.ក ៧ / ២០០៧

រាជធានីភ្នំពេញ, ថ្ងៃទី.០៥....ខែ.ធ្នូ ឆ្នាំ២០០៧

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

ជម្រាបមក

**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ**
**ឯកឧត្តម ប្រធានស្ថាប័ន គ្រប់អង្គភាពចំណុះក្រសួងការពារជាតិ**

**កម្មវត្ថុ** : ស្តីពី ការបំពេញជីវប្រវត្តិពិស្តារ ចំពោះយោធិនស្ថិតក្នុងស្ថានភាពចូលនិវត្តន៍តាមការកំណត់ ។

**យោង** : - អនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ។

- ប្រកាសលេខ ០១២ ប្រ.ក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់ក្រសួងការពារជាតិ ស្តីពីការណែនាំអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ។

តាមកម្មវត្ថុ និង យោងខាងលើ ដើម្បីមានមូលដ្ឋានក្នុងការពិគ្រោះដោះស្រាយគោលនយោបាយដល់យោធិនដែលស្ថិតក្នុងស្ថានភាពចូលនិវត្តន៍តាមការកំណត់ ស្របតាមគោលនយោបាយកំពុងប្រើរបស់កងយោធពលខេមរភូមិន្ទ សូមឯកឧត្តមចាត់តាំងឱ្យបណ្តាអង្គភាពដែលមានចំនួនយោធិនស្ថិតក្នុងស្ថានភាពចូលនិវត្តន៍តាមការកំណត់ឱ្យបំពេញជីវប្រវត្តិពិស្តារផ្ញើមកអគ្គនាយកដ្ឋានយោធសេវា (នាយកដ្ឋានសោធននិវត្តន៍) ឱ្យបានមុនថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៨ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម ប្រធានស្ថាប័នអង្គភាពចាត់ចែងអនុវត្តន៍តាមការគួរ ។

សូមឯកឧត្តម ទទួលការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

រដ្ឋមន្ត្រី

នាយឧ.ត្តមសេនីយ៍ ទៀ-បាញ់